បោះពុម្ពនៅរោងពុម្ព ទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី១ ចំនួន ១.៥០០ ច្បាប់

តម្លៃ ២.៧៥០ រៀល

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៧ លេខ ៥ ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

# រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រី រៀងរាល់សប្តាហ៍

# វិ

# មាតិកា

## I- ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


០៦-០២-១៩៩៩ -ព្រះរាជក្រឹត្យ នស/រកត/០២៩៩/២៩ តែងតាំងឯកឧត្តម អូន ព័ន្ធមុនីរ័ត្ន ជាអគ្គលេខាធិការនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ១៦៦

០៦-០២-១៩៩៩ -ព្រះរាជក្រឹត្យ នស/រកត/០២៩៩/៣០ ផ្លាស់ប្តូរមុខងារ និងតំណែងឋានន្តរសក្តិនាយកទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ១៦៥


## II- រាជរដ្ឋាភិបាល

### ១- អនុក្រឹត្យ


០២-០២-១៩៩៩ -អនុក្រឹត្យលេខ ០៩ អនក្រ.បក ស្តីពីការផ្ទេរឥណទាន ១៧១

០៣-០២-១៩៩៩ -អនុក្រឹត្យលេខ១០ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ [illegible] ១៧២

០៤-០២-១៩៩៩ -អនុក្រឹត្យលេខ ១៦ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៧៩

០៤-០២-១៩៩៩ -អនុក្រឹត្យលេខ ១៧ អនក្រ.តត ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល តំណាងភាគីរដ្ឋនៃក្រុមហ៊ុនចំរុះសហគ្រាសឱសថកម្ពុជា “ស.ឱ.ក” ១៧៩

០៤-០២-១៩៩៩ -អនុក្រឹត្យលេខ ១៨ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៨០

០៤-០២-១៩៩៩ -អនុក្រឹត្យលេខ ១៩ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៨១

០៤-០២-១៩៩៩ -អនុក្រឹត្យលេខ ២០ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៨២

០៤-០២-១៩៩៩ -អនុក្រឹត្យលេខ ២១ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៨៣

០៤-០២-១៩៩៩ -អនុក្រឹត្យលេខ ២២ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៨៣

០៤-០២-១៩៩៩ -អនុក្រឹត្យលេខ ២៣ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៨៤

០៤-០២-១៩៩៩ -អនុក្រឹត្យលេខ ២៤ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៨៥

០៤-០២-១៩៩៩ -អនុក្រឹត្យលេខ ២៥ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៨៦

០៤-០២-១៩៩៩ -អនុក្រឹត្យលេខ ២៦ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៨៦

០៤-០២-១៩៩៩ -អនុក្រឹត្យលេខ ២៧ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៨៧

០៥-០២-១៩៩៩ -អនុក្រឹត្យលេខ ២៨ អនក្រ.តត ស្តីពីការតែងតាំង ផ្លាស់ប្តូរមុខងារ និង តំលើងឋានន្តរសក្តិនាយទាហាននៃកងយោធពលខេមរភូមិន្ទ ១៨៩
០៥-០២-១៩៩៩ -អនុក្រឹត្យលេខ ២៩ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៩០
០៨-០២-១៩៩៩ -អនុក្រឹត្យលេខ ៣០ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៩១
០៨-០២-១៩៩៩ -អនុក្រឹត្យលេខ ៣១ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៩២
០៨-០២-១៩៩៩ -អនុក្រឹត្យលេខ ៣២ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៩២
០៨-០២-១៩៩៩ -អនុក្រឹត្យលេខ ៣៣ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៩៣

## ២- សេចក្តីសំរេច

០៥-០២-១៩៩៩ -សេចក្តីសំរេចលេខ ០៩ សសរ ស្តីពីការផ្ទេរភារកិច្ច ១៩៤
០៥-០២-១៩៩៩ -សេចក្តីសំរេចលេខ ១០ សសរ ស្តីពីការផ្ទេរភារកិច្ច ១៩៥
០៥-០២-១៩៩៩ -សេចក្តីសំរេចលេខ ១១ សសរ ស្តីពីការអនុញ្ញាតជាគោលការណ៍ឲ្យ ក្រុមហ៊ុន AZ Distribution Co., Ltd អភិវឌ្ឍន៍ និងពង្រីកបន្ថែមនូវ ប្រព័ន្ធ និងសេវាទូរគមនាគមន៍ជាតិទូទាំងព្រះរាជាណាចក្រកម្ពុជា ១៩៦
០៨-០២-១៩៩៩ -សេចក្តីសំរេចលេខ ១២ សសរ ស្តីពីការផ្ទេរសិទ្ធិ ១៩៧

# III- ការងារមណ្ឌលក្រសួង

## ១- លិខិតការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

### ប្រកាស

០១-០២-១៩៩៩ -ប្រកាសលេខ៣៦០MOC/៩៩ ស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រងកូតា សំរាប់ការនាំចេញ វាយនភ័ណ្ឌនិងផលិតផលវាយនភ័ណ្ឌ ដែលជាកម្មវត្ថុ នៃការកំណត់បរិមាណ ដោយសហរដ្ឋអាមេរិក ១៩៨

## ២- លិខិតការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

### ប្រកាស

០២-០២-១៩៩៩ -ប្រកាសលេខ ៧៤ ឧក.ប្រក អនុញ្ញាតឲ្យក្រុមហ៊ុនសាមូរ៉ៃ ប្លាស្ទិក ផេកខេជីង (ខេមបូឌា) អិលធីឌីតំណាងដោយលោក WEE SANG HONG សញ្ជាតិម៉ាឡេស៊ី បង្កើតរោងចក្រផលិតថង់ប្លាស្ទិក ២១៥

## ៣- លិខិតរដ្ឋមន្ត្រីក្រសួងព័ត៌មាន

០១-០២-១៩៩៩ -ប្រកាសលេខ ០០៦៨/៩៩ ពម.ប្រក ស្តីពីការតែងតាំងមន្ត្រីរាជការ ២១៦

## ៤- ទីស្តីការគណៈរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

### ប្រកាស

០២-០២-១៩៩៩ -ប្រកាសលេខ ៤៩ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ ព្រែកក្របៅ ស្ថិតនៅក្នុងឃុំ ព្រែកក្របៅ ស្រុកពាមជរ ខេត្តព្រៃវែង ២១៧

០២-០២-១៩៩៩ -ប្រកាសលេខ ៥០ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ ឌី ប៊ុក ក្នុងឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ២១៨

០២-០២-១៩៩៩ -ប្រកាសលេខ ៥១ អយក.ប្រក ស្តីពីការប្តូរឈ្មោះអនុវិទ្យាល័យ កន្តោរ ទៅជាអនុវិទ្យាល័យអង្គស្នួរពី ស្ថិតនៅក្នុងខេត្ត កំពត ២២០

០២-០២-១៩៩៩ -ប្រកាសលេខ ៥២ អយក.ប្រក ស្តីពីការពង្រីកអនុវិទ្យាល័យ ស្រែអំបិល ទៅជាវិទ្យាល័យ ស្រែអំបិល ស្ថិតនៅក្នុងឃុំស្រែអំបិល ស្រុកស្រែអំបិល ខេត្តកោះកុង ២២១

០២-០២-១៩៩៩ -ប្រកាសលេខ ៥៣ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ ហ៊ុន សែន "សម្តេច ពាន់" ស្ថិតនៅក្នុងឃុំក្តាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ ២២២

០២-០២-១៩៩៩ -ប្រកាសលេខ ៥៤ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន "នារាយណ៍" ស្ថិតនៅក្នុងឃុំនារាយណ៍ ស្រុក ឈូក ខេត្តកំពត ២២៣

០២-០២-១៩៩៩ -ប្រកាសលេខ ៥៥ អយក.ប្រក ស្តីពីការបើកវិទ្យាល័យ ហ៊ុន សែន "មង្គលបូរី" ស្ថិតនៅក្នុងឃុំឫស្សីក្រោក ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ២២៥

០២-០២-១៩៩៩ -ប្រកាសលេខ ៥៦ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ សមរលាភ ស្ថិតនៅក្នុងឃុំពោធិ៍រំចាក ស្រុកព្រៃកប្បាស ខេត្តតាកែវ ២២៦

០២-០២-១៩៩៩ -ប្រកាសលេខ ៥៧ អយក.ប្រក ស្តីពីការពង្រីកអនុវិទ្យាល័យ ហ៊ុន សែន "ចំការដូង" ទៅជាវិទ្យាល័យ ហ៊ុន សែន "ចំការដូង" ស្ថិតនៅខណ្ឌកែប ក្រុងកែប ២២៧

០២-០២-១៩៩៩ -ប្រកាសលេខ ៥៨ អយក.ប្រក ស្តីពីការបញ្ចូលអនុវិទ្យាល័យកំពង់ត្រាច ជាមួយវិទ្យាល័យ ព្រះបិតា ចរិកាជាតិ ក្នុងខេត្តកំពត ២២៨

# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រឹត្យ

### ព្រះរាជក្រឹត្យ នស/រកត/០២៩៩/២៩

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជាធិរាជ ឧត្តមរាជ វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ ១៩៩៩

ត្រាស់បង្គាប់

**មាត្រា ១ .-** តែងតាំងឯកឧត្តម នួន ព័ន្ធឫទ្ធិរ័ត្ន ជាអគ្គលេខាធិការនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២ .-** ព្រះរាជក្រឹត្យលេខ ជស/រកត/០៧៩៦/២៩ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ១៩៩៦ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ .-** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចព្រះរាជក្រឹត្យនេះ។

**មាត្រា ៤ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ ១៩៩៩

ព្រះហស្ថលេខា

នរោត្តម សីហនុ

***

# ព្រះរាជក្រឹត្យ នស/រកត/០២៩៩/៣០

## យើង

## ព្រះបាទសម្ដេចព្រះ នរោត្ដម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្ដម

## ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

***

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/២១ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៩ ស្ដីពីការកែសម្រួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធតាត់តាំងអគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់ សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ .-** ត្រូវបានតែងតាំងផ្លាស់ប្ដូរមុខងារ និងតំឡើងឋានន្តរសក្ដិនាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម ៖

| | | | | |
|---|---|---|---|---|
| ១- ឧត្ដមសេនីយ៍ឯក | ប៉ាន់ | ថៃ | បច្ចុប្បន្នជា | ទីប្រឹក្សា ក្រសួងការពារជាតិ |
| ២- ឧត្ដមសេនីយ៍ឯក | ម៉ុល | សុត | បច្ចុប្បន្នជា | ទីប្រឹក្សា ក្រសួងការពារជាតិ |
| ៣- ឧត្ដមសេនីយ៍ទោ | ស៊ើយ | កែវ | បច្ចុប្បន្នជា | ទីប្រឹក្សា ក្រសួងការពារជាតិ និងជា ឧត្ដមសេនីយ៍ឯក |
| ៤- ឧត្ដមសេនីយ៍ទោ | ផា | ផនចាន់ | បច្ចុប្បន្នជា | ទីប្រឹក្សា ក្រសួងការពារជាតិ |
| ៥- ឧត្ដមសេនីយ៍ត្រី | ម៉ិន | គង | បច្ចុប្បន្នជា | ទីប្រឹក្សា ក្រសួងការពារជាតិ និងជា ឧត្ដមសេនីយ៍ទោ |
| ៦- ឧត្ដមសេនីយ៍ត្រី | កែវ | វិបុល | បច្ចុប្បន្នជា | ទីប្រឹក្សា ក្រសួងការពារជាតិ |
| ៧- ឧត្ដមសេនីយ៍ត្រី | សែន | សុផុន | បច្ចុប្បន្នជា | ទីប្រឹក្សា ក្រសួងការពារជាតិ |
| ៨- ឧត្ដមសេនីយ៍ត្រី | ស៊ឿង | ឫទ្ធិសក្ដិ | បច្ចុប្បន្នជា | ទីប្រឹក្សា ក្រសួងការពារជាតិ |
| ៩- ឧត្ដមសេនីយ៍ត្រី | ហែម | ក្រាញ់ឆ្លាក់ | បច្ចុប្បន្នជា | ទីប្រឹក្សា ក្រសួងការពារជាតិ |
| ១០- ឧត្ដមសេនីយ៍ទោ | ញ៉ឹក | ឈួន | បច្ចុប្បន្នជា | ទីប្រឹក្សា អគ្គមេបញ្ជាការ |
| ១១- ឧត្ដមសេនីយ៍ទោ | ស៊ូ | គឹមស៊ុន | បច្ចុប្បន្នជា | ទីប្រឹក្សា អគ្គមេបញ្ជាការ |
| ១២- ឧត្ដមសេនីយ៍ទោ | គឹម | ឆាង | បច្ចុប្បន្នជា | ទីប្រឹក្សា អគ្គមេបញ្ជាការ |

១៣- ឧត្តមសេនីយ៍ទោ ប្រូចថ ប៊ុនថុល បច្ចុប្បន្នជា ទីប្រឹក្សា អគ្គមេបញ្ជាការ

១៤- ឧត្តមសេនីយ៍ទោ លី ដេត បច្ចុប្បន្នជា ទីប្រឹក្សា អគ្គមេបញ្ជាការ

១៥- ឧត្តមសេនីយ៍ទោ គាន់ រ៉ាត់ បច្ចុប្បន្នជា ទីប្រឹក្សា អគ្គមេបញ្ជាការ

១៦- ឧត្តមសេនីយ៍ទោ ហេង មុរិន្ទ បច្ចុប្បន្នជា ទីប្រឹក្សា អគ្គមេបញ្ជាការ បន្ថែមលើមុខងារបច្ចុប្បន្ន

១៧- ឧត្តមសេនីយ៍ត្រី នី មុត្រ បច្ចុប្បន្នជា ទីប្រឹក្សា អគ្គមេបញ្ជាការ និងជា ឧត្តមសេនីយ៍ទោ

១៨- ឧត្តមសេនីយ៍ត្រី ពុន សំអោក បច្ចុប្បន្នជា ទីប្រឹក្សា អគ្គមេបញ្ជាការ និងជា ឧត្តមសេនីយ៍ទោ

១៩- ឧត្តមសេនីយ៍ត្រី ស៊ិន ចាន់ បច្ចុប្បន្នជា ទីប្រឹក្សា អគ្គមេបញ្ជាការ និងជា ឧត្តមសេនីយ៍ទោ

២០- ឧត្តមសេនីយ៍ត្រី ម៉ើន វិចិត្រ បច្ចុប្បន្នជា មេបញ្ជាការរងកងរាជអាវុធហត្ថ

២១- វរសេនីយ៍ឯក គេង ឈួន បច្ចុប្បន្នជា មេបញ្ជាការរងកងរាជអាវុធហត្ថ និងជា ឧត្តមសេនីយ៍ត្រី

២២- វរសេនីយ៍ឯក ទន្សូ ពិសេន បច្ចុប្បន្នជា មេបញ្ជាការរង និង ជានាយសេនាធិការកងរាជអាវុធហត្ថ និងជា ឧត្តមសេនីយ៍ត្រី

២៣- ឧត្តមសេនីយ៍ត្រី ម៉ម សុផាត បច្ចុប្បន្នជា នាយកឧទ្ទកាល័យអគ្គបញ្ជាការដ្ឋាន និងជាឧត្តមសេនីយ៍ទោ

២៤- ឧត្តមសេនីយ៍ត្រី ហេង ចំរើន បច្ចុប្បន្នជា នាយករងឧទ្ទកាល័យអគ្គបញ្ជាការដ្ឋាន

២៥- វរសេនីយ៍ឯក សេង ទ៉ាន់ធី បច្ចុប្បន្នជា នាយករងឧទ្ទកាល័យអគ្គបញ្ជាការដ្ឋាន និងជាឧត្តមសេនីយ៍ត្រី

២៦- វរសេនីយ៍ឯក ឌុំវ សារុន បច្ចុប្បន្នជា នាយករងឧទ្ទកាល័យអគ្គបញ្ជាការដ្ឋាន និងជាឧត្តមសេនីយ៍ត្រី

២៧- ឧត្តមសេនីយ៍ទោ ឌុំ សម្បូរ បច្ចុប្បន្នជា នាយកអធិការកិច្ចអគ្គបញ្ជាការដ្ឋាន

២៨- ឧត្តមសេនីយ៍ត្រី មុំ សោភ័ណ្ឌ បច្ចុប្បន្នជា នាយករងអធិការកិច្ចអគ្គបញ្ជាការដ្ឋាន

២៩- ឧត្តមសេនីយ៍ទោ សេនា សក្តិ បច្ចុប្បន្នជា នាយកមជ្ឈមណ្ឌលស្រាវជ្រាវប្រវត្តិសាស្ត្រយោធា អគ្គមេបញ្ជាការដ្ឋាន

៣០- ឧត្តមសេនីយ៍ត្រី ហ៊ុយ កែវ បច្ចុប្បន្នជា នាយករងមជ្ឈមណ្ឌលស្រាវ

| | | | |
|---|---|---|---|
| | | | ស្រាវជ្រាវប្រវត្តិសាស្ត្រយោធាអគ្គបញ្ជាការដ្ឋាន |
| ៣១- ឧត្តមសេនីយ៍ត្រី | ហ៊ី | ចាន់នី | បច្ចុប្បន្នជា នាយករងមជ្ឈមណ្ឌលស្រាវជ្រាវប្រវត្តិសាស្ត្រយោធាអគ្គមេបញ្ជាការដ្ឋាន |
| ៣២- ឧត្តមសេនីយ៍ត្រី | មាស | សុវណ្ណ | បច្ចុប្បន្នជា នាយករងមជ្ឈមណ្ឌលស្រាវជ្រាវប្រវត្តិសាស្ត្រយោធាអគ្គបញ្ជាការដ្ឋាន |
| ៣៣- ឧត្តមសេនីយ៍ត្រី | ដាំ | វុឌ្ឍី | បច្ចុប្បន្នជា នាយកទីចាត់ការបុគ្គលិកអគ្គបញ្ជាការដ្ឋាន និងជាឧត្តមសេនីយ៍ទោ |
| ៣៤- ឧត្តមសេនីយ៍ត្រី | ម៉ក់ | សារុន | បច្ចុប្បន្នជា នាយកទីចាត់ការចលនូបត្ថម្ភអគ្គបញ្ជាការដ្ឋាននិងជាឧត្តមសេនីយ៍ទោ |
| ៣៥- ឧត្តមសេនីយ៍ត្រី | ធូ | ស៊ុន | បច្ចុប្បន្នជា នាយកទីចាត់ការឃោសនានិងព័ត៌មាន អគ្គបញ្ជាការដ្ឋាន និងជាឧត្តមសេនីយ៍ទោ |
| ៣៦- ឧត្តមសេនីយ៍ត្រី | ឥត | សារ៉ាត់ | បច្ចុប្បន្នជា នាយកទីចាត់ការហ្វឹកហ្វឺនអគ្គបញ្ជាការដ្ឋាន និងជាឧត្តមសេនីយ៍ទោ |
| ៣៧- ឧត្តមសេនីយ៍ត្រី | ទ៉ាន | ប៊ុន្នី | បច្ចុប្បន្នជា នាយករងទីចាត់ហ្វឹកហ្វឺនអគ្គបញ្ជាការដ្ឋាន |
| ៣៨- ឧត្តមសេនីយ៍ត្រី | ខ្វាន់ | ស៊ាម | បច្ចុប្បន្នជា មេបញ្ជាការកងវិស្វកម្មអគ្គបញ្ជាការដ្ឋាន និងជាឧត្តមសេនីយ៍ទោ |
| ៣៩- ឧត្តមសេនីយ៍ទោ | ឈុំ | សុជាតិ | បច្ចុប្បន្នជា នាយកទីចាត់ការការងារព្រំដែន អគ្គបញ្ជាការដ្ឋាន |
| ៤០- ឧត្តមសេនីយ៍ត្រី | នួន | តារា | បច្ចុប្បន្នជា នាយករងទីចាត់ការព្រំដែនអគ្គបញ្ជាការដ្ឋាន |
| ៤១- ឧត្តមសេនីយ៍ត្រី | ដួង | សុខុន | បច្ចុប្បន្នជា នាយករងទីចាត់ការការងារព្រំដែនអគ្គបញ្ជាការដ្ឋាន |
| ៤២- ឧត្តមសេនីយ៍ត្រី | អ៊ុយ | សារិន | បច្ចុប្បន្នជា នាយករងទីចាត់ការការងារព្រំដែនអគ្គបញ្ជាការដ្ឋាន |
| ៤៣- ឧត្តមសេនីយ៍ត្រី | ឡាញ់ | កៅ | បច្ចុប្បន្នជា មេបញ្ជាការកងរថក្រោះ អគ្គបញ្ជាការដ្ឋាន និងជាឧត្តមសេនីយ៍ទោ |
| ៤៤- ឧត្តមសេនីយ៍ត្រី | សួន | សារ៉ាឯម | បច្ចុប្បន្នជា នាយសេនាធិការកងអន្តរាគមន៍អគ្គបញ្ជាការដ្ឋាន និងជាឧត្តមសេនីយ៍ទោ |

| | | | |
|---|---|---|---|
| ៤៥- ឧត្តមសេនីយ៍ត្រី | លឹម | ម៉ុនធឿន | បច្ចុប្បន្នជា នាយសេនាធិការរងកងអគ្គភាគមន៍ អគ្គបញ្ជាការដ្ឋាន |
| ៤៦- ឧត្តមសេនីយ៍ត្រី | ឡុង | សេរីវឌ្ឍ | បច្ចុប្បន្នជានាយសេនាធិការរងកងអគ្គភាគមន៍ អគ្គបញ្ជាការដ្ឋាន |
| ៤៧- ឧត្តមសេនីយ៍ត្រី | ឃាង | សាវីន | បច្ចុប្បន្នជានាយសេនាធិការរងកងអគ្គភាគមន៍ អគ្គបញ្ជាការដ្ឋាន |
| ៤៨- ឧត្តមសេនីយ៍ត្រី | សាន់ | ភារីសតី | បច្ចុប្បន្នជានាយសេនាធិការរងកងអគ្គភាគមន៍ អគ្គបញ្ជាការដ្ឋាន |
| ៤៩- ឧត្តមសេនីយ៍ត្រី | ចាន់ | ពៅ | បច្ចុប្បន្នជានាយសេនាធិការរងកងអគ្គភាគមន៍ អគ្គបញ្ជាការដ្ឋាន |
| ៥០- ឧត្តមសេនីយ៍ត្រី | លី | គាត | បច្ចុប្បន្នជានាយសេនាធិការរងកងអគ្គភាគមន៍ អគ្គបញ្ជាការដ្ឋាន |
| ៥១- វរសេនីយ៍ឯក | សុខ | ស៊ាន | បច្ចុប្បន្នជានាយសេនាធិការរងកងអគ្គភាគមន៍ អគ្គបញ្ជាការដ្ឋាន និងជាឧត្តមសេនីយ៍ត្រី |
| ៥២- ឧត្តមសេនីយ៍ត្រី | អ៊ុន | ស៊ាន | បច្ចុប្បន្នជា នាយកបណ្ឌិតសភាយោធា អគ្គបញ្ជាការដ្ឋាន និងជាឧត្តមសេនីយ៍ទោ |
| ៥៣- ឧត្តមសេនីយ៍ត្រី | ប្រាក់ | សុវណ្ណា | បច្ចុប្បន្នជានាយកសាលានាយទាហានចំរុះ អគ្គបញ្ជាការដ្ឋាននិងជាឧត្តមសេនីយ៍ទោ |
| ៥៤- ឧត្តមសេនីយ៍ត្រី | ខៀវ | ទិះ | បច្ចុប្បន្នជា នាយករង ទីចាត់ការកលយុទ្ធ អគ្គបញ្ជាការដ្ឋាន |
| ៥៥- ឧត្តមសេនីយ៍ត្រី | ម៉ី | ម៉ិន | បច្ចុប្បន្នជា នាយករង ទីចាត់ការកលយុទ្ធ អគ្គបញ្ជាការដ្ឋាន |
| ៥៦- ឧត្តមសេនីយ៍ត្រី | ប្រាក់ | សំអុល | បច្ចុប្បន្នជា នាយករង ទីចាត់ការកលយុទ្ធ អគ្គបញ្ជាការដ្ឋាន |
| ៥៧- ឧត្តមសេនីយ៍ត្រី | កែន | សុវណ្ណ | បច្ចុប្បន្នជា នាយករង ទីចាត់ការកលយុទ្ធ អគ្គបញ្ជាការដ្ឋាន |
| ៥៨- ឧត្តមសេនីយ៍ត្រី | ងួ | ហៀង | បច្ចុប្បន្នជា នាយករង ទីចាត់ការកលយុទ្ធ អគ្គបញ្ជាការដ្ឋាន |
| ៥៩- ឧត្តមសេនីយ៍ត្រី | ម៉ៅ | សុវណ្ណ | បច្ចុប្បន្នជា នាយករង ទីចាត់ការកលយុទ្ធ អគ្គបញ្ជាការដ្ឋាន |
| ៦០- ឧត្តមសេនីយ៍ត្រី | ជា | កែវ | បច្ចុប្បន្នជា នាយករងទីចាត់ការកលយុទ្ធ អគ្គបញ្ជាការដ្ឋាន |

| | | | |
|---|---|---|---|
| ៦១- វរសេនីយ៍ឯក | អន | គឹមសន | បច្ចុប្បន្នជា នាយករង ទីចាត់ការកលយុទ្ធ អគ្គបញ្ជាការដ្ឋាន និងជាឧត្តមសេនីយ៍ត្រី |
| ៦២- វរនាវីឯក | នួន | ទ័ន | បច្ចុប្បន្នជា នាយករង ទីចាត់ការកលយុទ្ធ អគ្គបញ្ជាការដ្ឋាន និងជាឧត្តមសេនីយ៍ត្រី |
| ៦៣- ឧត្តមសេនីយ៍ត្រី | អ៊ុល | ណារី | បច្ចុប្បន្នជាមេបញ្ជាការកងការពារអាកាស អគ្គបញ្ជាការដ្ឋាន |
| ៦៤- ឧត្តមសេនីយ៍ត្រី | ចាប | គន្ធី | បច្ចុប្បន្នជាមេបញ្ជាការកងទ័ពពិសេស ត្រៃលោក អគ្គបញ្ជាការដ្ឋាន |
| ៦៥- ឧត្តមសេនីយ៍ត្រី | ជុំ | គុនហេង | បច្ចុប្បន្នជា នាយកទីចាត់ការអភិវឌ្ឍន៍ អគ្គបញ្ជាការដ្ឋាន |
| ៦៦- វរសេនីយ៍ឯក | យឹម | សាញ់ | បច្ចុប្បន្នជា មេបញ្ជាការកងកាំភ្លើងធំ អគ្គបញ្ជាការដ្ឋាន និងជាឧត្តមសេនីយ៍ត្រី |
| ៦៧- វរសេនីយ៍ឯក | ម៉ែគ | ម៉ុន្នី | បច្ចុប្បន្នជា មេបញ្ជាការកងបញ្ជូនសារ អគ្គបញ្ជាការដ្ឋាន និងជាឧត្តមសេនីយ៍ត្រី |
| ៦៨- វរសេនីយ៍ឯក | លី | សុវណ្ណ | បច្ចុប្បន្នជា នាយកទីចាត់ការសុខាភិបាល អគ្គបញ្ជាការដ្ឋាន និងជាឧត្តមសេនីយ៍ត្រី |
| ៦៩- វរសេនីយ៍ឯក | អ៊ុ | សារុំ | បច្ចុប្បន្នជា នាយកទីចាត់ការហិរញ្ញវត្ថុ អគ្គបញ្ជាការដ្ឋាន និងជាឧត្តមសេនីយ៍ត្រី |
| ៧០- វរសេនីយ៍ឯក | ពន | សុខ | បច្ចុប្បន្នជា នាយក ទីចាត់ការផែនការ អគ្គបញ្ជាការដ្ឋាន និងជាឧត្តមសេនីយ៍ត្រី |
| ៧១- វរសេនីយ៍ឯក | យ៉ាល់ | ពិសិដ្ឋ | បច្ចុប្បន្នជា នាយក ទីចាត់ការបច្ចេកទេស អគ្គបញ្ជាការដ្ឋាន និងជាឧត្តមសេនីយ៍ត្រី |
| ៧២- វរសេនីយ៍ឯក | សៅ | គប | បច្ចុប្បន្នជា នាយក ទីចាត់ការបរិក្ខាអគ្គរៈ អគ្គបញ្ជាការដ្ឋាន និងជាឧត្តមសេនីយ៍ត្រី |
| ៧៣- វរសេនីយ៍ឯក | ពេជ្រ | ឈឿន | បច្ចុប្បន្នជានាយកសាលាជំនាញឯកទេស ចំរុះអគ្គបញ្ជាការដ្ឋាន និងជាឧត្តមសេនីយ៍ត្រី |
| ៧៤- ឧត្តមសេនីយ៍ត្រី | ម៉ៅ | ឆែន | បច្ចុប្បន្នជា នាយសេនាធិការរងកងទ័ពជើងគោក |
| ៧៥- ឧត្តមសេនីយ៍ត្រី | ម៉ាត់ | ដាឡា | បច្ចុប្បន្នជា នាយសេនាធិការរងកងទ័ពជើងគោក |
| ៧៦- ឧត្តមសេនីយ៍ត្រី | ព្រហ្ម | មរណៈ | បច្ចុប្បន្នជា នាយសេនាធិការរងកងទ័ពជើងគោក |

| | | | |
|---|---|---|---|
| ៧៧- ឧត្តមសេនីយ៍ត្រី | សុខ | ឈាន | បច្ចុប្បន្នជា នាយសេនាធិការរងកងទ័ពជើងគោក |
| ៧៨- ឧត្តមសេនីយ៍ត្រី | អ៊ុន | ហឿន | បច្ចុប្បន្នជា នាយសេនាធិការរងកងទ័ពជើងគោក |
| ៧៩- ឧត្តមសេនីយ៍ត្រី | អ៊ុត | ឈាង | បច្ចុប្បន្នជា នាយសេនាធិការរងនិងជានាយការិយាល័យទី៣ កងទ័ពជើងគោក |
| ៨០- ឧត្តមសេនីយ៍ត្រី | ជុំ | ហាត់ | បច្ចុប្បន្នជា នាយសេនាធិការរង និងជានាយការិយាល័យទី២ កងទ័ពជើងគោក |
| ៨១- ឧត្តមសេនីយ៍ត្រី | ចាន់ | សុគន្ធា | បច្ចុប្បន្នជា នាយសេនាធិការ និងជានាយការិយាល័យហ្វឹកហ្វឺន កងទ័ពជើងគោក |
| ៨២- ឧត្តមសេនីយ៍ត្រី | សែន | ចំរុង | បច្ចុប្បន្នជា នាយអធិការកិច្ចកងទ័ពជើងគោក |
| ៨៣- វរសេនីយ៍ឯក | អ៊ឹម | វេជ្ជា | បច្ចុប្បន្នជានាយឧទ្ទកាល័យកងទ័ពជើងគោក និងជា ឧត្តមសេនីយ៍ត្រី |
| ៨៤- វរសេនីយ៍ឯក | អ៊ុន | លន | បច្ចុប្បន្នជា នាយការិយាល័យទី១ កងទ័ពជើងគោក និងជា ឧត្តមសេនីយ៍ត្រី |
| ៨៥- វរសេនីយ៍ឯក | កែន | តារា | បច្ចុប្បន្នជា នាយការិយាល័យទី៤ កងទ័ពជើងគោក និងជាឧត្តមសេនីយ៍ត្រី |
| ៨៦- វរសេនីយ៍ឯក | ខៀវ | និត | បច្ចុប្បន្នជា នាយការិយាល័យទី៥ កងទ័ពជើងគោក និងជា ឧត្តមសេនីយ៍ត្រី |
| ៨៧- វរសេនីយ៍ឯក | ចាប | ទំនឹ | បច្ចុប្បន្នជា នាយការិយាល័យអេកាធាត់បង់ កងទ័ពជើងគោក និងជា ឧត្តមសេនីយ៍ត្រី |
| ៨៨- វរសេនីយ៍ឯក | អ៊ុច | ទ័ាន់ថា | បច្ចុប្បន្នជា នាយការិយាល័យវិស្វកម្ម កងទ័ពជើងគោក និងជា ឧត្តមសេនីយ៍ត្រី |
| ៨៩- វរសេនីយ៍ឯក | ពៅ | ស៊ីថា | បច្ចុប្បន្នជា នាយការិយាល័យរថពាសដែក កងទ័ពជើងគោក និងជា ឧត្តមសេនីយ៍ត្រី |
| ៩០- ឧត្តមសេនីយ៍ត្រី | ខាត | គង់ | បច្ចុប្បន្នជា មេបញ្ជាការយោធភូមិភាគទី១ និងជាឧត្តមសេនីយ៍ទោ |
| ៩១- ឧត្តមសេនីយ៍ត្រី | ចាន់ | សុខុម | បច្ចុប្បន្នជាមេបញ្ជាការរងយោធភូមិភាគទី១ |
| ៩២- វរសេនីយ៍ឯក | ហេង | ខាំទ៉ាន់ | បច្ចុប្បន្នជាមេបញ្ជាការរងយោធភូមិភាគទី១ និងជា ឧត្តមសេនីយ៍ត្រី |
| ៩៣- ឧត្តមសេនីយ៍ត្រី | សោម | ណារិន | បច្ចុប្បន្នជាមេបញ្ជាការរងយោធភូមិភាគទី៣ |

៩៥- ឧត្តមសេនីយ៍ត្រី អៀង ផាន បច្ចុប្បន្នជាមេបញ្ជាការរងយោធភូមិភាគទី៥

មាត្រា ២ .- នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ឲ្យបានសំរេច ។

មាត្រា ៣ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះ តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

ព្រះហស្ថលេខា

នរោត្តម សីហនុ

***

# II- រាជរដ្ឋាភិបាល

## ១.អនុក្រឹត្យ

### អនុក្រឹត្យលេខ ០៩ អនក្រ.បក

### ស្តីពីការផ្ទេរឥណទាន

* * *

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រម ០៧/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រម នស/រកម/០១៩៩/០១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ១៩៩៩
- បានឃើញ អនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការបែងចែកឥណទានថវិកាជំពូកតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ១៩៩៩

- បានឃើញ អនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការផ្ទេរចំណូល និងផ្ទេរឥណទានថវិកា សំរាប់ក្រសួង-ស្ថាប័នថ្មី
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**សំរេច**

**មាត្រា ១ .-** ត្រូវបានអនុញ្ញាតឲ្យផ្ទេរឥណទានថវិកា ចំនួន ៣.៤២២ លានរៀល (បីពាន់បួនរយម្ភៃពីរលានរៀល) ពីជំពូក ៤១ (ចំណាយឥតគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក ៣១ (អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌) របស់ទីស្តីការគណៈរដ្ឋមន្ត្រី សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៩ ។

**មាត្រា ២ .-** ឥណទានថវិកាក្នុងមាត្រា១ ខាងលើ ត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ សំរាប់ទូទាត់សងថ្លៃទិញអង្ករ ២.០០០តោន ឧបត្ថម្ភជូនបងប្អូនប្រជាពលរដ្ឋផ្តាច់ខ្លួន វិលមករួមរស់ក្នុងសង្គមជាតិវិញចុងឆ្នាំ ១៩៩៨ ។

**មាត្រា ៣ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

***

## អនុក្រឹត្យលេខ ១០ អនក្រ.បក
## ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ
## របស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា

* * *

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃ២០ ខែកក្កដា ឆ្នាំ១៩៩៤ ប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ អនុក្រឹត្យលេខ ១១៦ អនក្រ. ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីចំណាត់តាំង និង សកម្មភាពរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា

- បានឃើញ អនុក្រឹត្យលេខ ១២ អនក្រ.តុ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងសមាសភាពថ្មី នៃគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា
- តាមសំណើរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា

## សំរេច

## ជំពូក ១

## បទបញ្ញត្តិទូទៅ

មាត្រា ១ .- អនុក្រឹត្យនេះរៀបចំបណ្តាអង្គភាព នៃគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា និងកំណត់បេសកកម្មរបស់ស្ថាប័ន និងមុខងារនៃអគ្គលេខាធិការដ្ឋាន និងបណ្តានាយកដ្ឋាននានាដែលស្ថិតនៅក្រោមឱវាទ នៃគណៈកម្មាធិការនេះ ។

## ជំពូក ២

## បេសកកម្ម និង រចនាសម្ព័ន្ធ

មាត្រា ២ .- គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជាហៅកាត់ថា "គជទមក ឬ CNMC" ជាស្ថាប័នជាតិមួយចំពោះរាជរដ្ឋាភិបាលមានតួនាទីជាសេនាធិការ ជំនួយការនិងការផ្តល់យោបល់ជូនរាជរដ្ឋាភិបាល លើរាល់ការកសាងនយោបាយទឹក ការរៀបចំយុទ្ធសាស្ត្រ ការងារគ្រប់គ្រង ការថែរក្សា ការសិក្សា ការធ្វើផែនការ ការស្តារ និងធ្វើអាជីវកម្មលើធនធានទឹក និងធនធានដទៃទៀត ដែលពាក់ព័ន្ធក្នុងអាងទន្លេមេគង្គ ក្នុងក្របខ័ណ្ឌទូទាំងប្រទេស ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍន៍ជានិរន្តរ៍ នៃសេដ្ឋកិច្ចសង្គម និងហេដ្ឋារចនាសម្ព័ន្ធជាតិ ដើម្បីជាផលប្រយោជន៍ជាតិ និង ប្រជារាស្ត្រ ។

មាត្រា ៣ .- គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជាមានមុខងារ និង ភារកិច្ចដូចតទៅ :

១- ធ្វើការសិក្សាពិនិត្យពិចារណា ដោយលើកសំណើជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យសំរេចលើរាល់បញ្ហាទាំងឡាយ ដែលទាក់ទងនឹងការធ្វើផែនការ ការរៀបចំយុទ្ធសាស្ត្រ ស្តីពីការអភិវឌ្ឍន៍ ព្រមទាំងការគ្រប់គ្រង និងថែរក្សាការពារធនធានទឹក និងធនធានដទៃទៀត ដែលពាក់ព័ន្ធក្នុងអាងទន្លេមេគង្គ ។

២- រួមសហការណែនាំ តាមដានបណ្តាផ្នែកនៃក្រសួងពាក់ព័ន្ធ ដើម្បីអនុវត្តសេចក្តីសំរេចទាំងឡាយរបស់រាជរដ្ឋាភិបាលស្តីពីទន្លេមេគង្គ ។

៣- ពង្រឹងសហប្រតិបត្តិការ ជាមួយនឹងគណៈកម្មាធិការជាតិទន្លេមេគង្គ នៃប្រទេសជាសមាជិក ជាមួយបណ្តាប្រទេសផ្តល់ជំនួយឯទៀត និង អង្គការអន្តរជាតិផ្សេងៗ ក្នុង ការពិនិត្យ ពិចារណា ការសិក្សា និងការអភិវឌ្ឍន៍ ការគ្រប់គ្រង និងថែរក្សាធនធានទឹក និង ធនធានដទៃទៀត ដែលពាក់ព័ន្ធនឹងទន្លេមេគង្គឲ្យបានសមស្របទៅនឹងផលប្រយោជន៍ដ៏សមរម្យរបស់បណ្តាប្រទេសជាសមាជិក ។

៤- ធ្វើការទំនាក់ទំនង សំរបសំរួលជាមួយគណៈកម្មការទន្លេមេគង្គ និងបណ្ដាសហគមន៍ផ្ដល់ជំនួយអន្តរជាតិនានា ដើម្បីស្វែងរកទុនជំរុញការសិក្សា និងអភិវឌ្ឍន៍គំរោងឲ្យបានឆាប់រហ័សទាន់ពេលវេលា និងមានប្រសិទ្ធភាពខ្ពស់ ។

មាត្រា ៤ .- គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ដឹកនាំដោយប្រធាន ០១រូប ថ្នាក់ស្មើនឹងរដ្ឋមន្ត្រី ជាអ្នកទទួលខុសត្រូវផ្ទាល់ចំពោះរាជរដ្ឋាភិបាល និង មានអនុប្រធានមួយចំនួនថ្នាក់យ៉ាងទាបស្មើនឹងរដ្ឋលេខាធិការរបស់បណ្ដាក្រសួង ជាជំនួយការ ។

មាត្រា ៥ .- គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជាមានសមាជិក :

- ក្រសួងសាធារណការ និង ដឹកជញ្ជូន
- ក្រសួងធនធានទឹក និងឧតុនិយម
- ក្រសួងបរិស្ថាន
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងផែនការ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងអភិវឌ្ឍន៍ជនបទ
- ក្រសួងទេសចរណ៍ ។

តំណាងអចិន្ត្រៃយ៍ នៃក្រសួងជាសមាជិកត្រូវមានថ្នាក់យ៉ាងទាបស្មើនឹងប្រធាននាយកដ្ឋាន ។

មាត្រា ៦ .- គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា មានគណៈកម្មការប្រតិបត្តិមួយ សំរាប់ដឹកនាំការងារប្រចាំថ្ងៃ ដែលមានសមាសភាពដូចតទៅ :

១- ប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា
២- បណ្ដាអនុប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា
៣- អគ្គលេខាធិការគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា
៤- បណ្ដាអគ្គលេខាធិការរងគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ។

មាត្រា ៧ .- រចនាសម្ព័ន្ធរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជាមាន :

- អគ្គលេខាធិការដ្ឋានដឹកនាំ ដោយអគ្គលេខាធិការ ០១រូប មានថ្នាក់ស្មើនឹងអនុរដ្ឋលេខាធិការរបស់បណ្ដាក្រសួង និងមានអគ្គលេខាធិការរងមួយចំនួនជាជំនួយការ មានថ្នាក់ស្មើអគ្គនាយកនៃក្រសួង ។
- បណ្ដានាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋានរួមមាន :
  - នាយកដ្ឋានរដ្ឋបាល-ហិរញ្ញវត្ថុ
  - នាយកដ្ឋានផែនការ
  - នាយកដ្ឋានបណ្ដាគំរោង

- នាយកដ្ឋាននីមួយៗ ត្រូវដឹកនាំដោយប្រធាន ០១រូប និងអនុប្រធាន ០១រូប ជាជំនួយការ លើកលែងមានការបែងចែកភារៈមួយចំនួនទៀត ។

អង្គការលេខរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ជាឧបសម្ព័ន្ធរបស់អនុក្រឹត្យនេះ ។

**មាត្រា ៨ .-** ភារកិច្ចរបស់បណ្ដាអង្គភាពចែងក្នុងមាត្រា៧ មានដូចតទៅ ៖

**៨.១ អគ្គលេខាធិការដ្ឋាន :**

- ធ្វើទំនាក់ទំនងសំរបសំរួលជាមួយលេខាធិការដ្ឋាន គណៈកម្មការទន្លេមេគង្គ និងគណៈកម្មាធិការជាតិទន្លេមេគង្គ នៃប្រទេសជាសមាជិកលើរាល់សកម្មភាពទាក់ទងនឹងបញ្ហាទន្លេមេគង្គ ។
- រាយការណ៍ និងផ្ដល់យោបល់ជូនប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ។
- សំរបសំរួលរាល់សកម្មភាព និងការងាររបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ។
- លើកគំរោងកម្មវិធីការងារ ដាក់ជូនគណៈកម្មការទន្លេមេគង្គ ស្របតាមទិសដៅផែនការ នៃការដឹកនាំរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ដើម្បីរកជំនួយ ។
- តាមដាន ណែនាំ និងវាយតំលៃលើផលសំរេច នៃការអនុវត្តន៍រាល់ការងារដែលជា ភារកិច្ចរបស់បណ្ដាអង្គភាពនៅក្នុងបន្ទុករបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា និងអង្គភាពនៃស្ថាប័នពាក់ព័ន្ធ ។
- បូកសរុបគ្រប់សកម្មភាព និងគ្រប់សភាពការណ៍នៃការងារ ដែលស្ថិតនៅក្នុងក្របខ័ណ្ឌ និងភារកិច្ចរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ។

**៨.២ នាយកដ្ឋានរដ្ឋបាល-ហិរញ្ញវត្ថុ :**

- ទទួលខុសត្រូវសេវាកម្មទូទៅក្នុងផ្នែករដ្ឋបាល និង ហិរញ្ញវត្ថុ ការផ្គត់ផ្គង់ និងព័ត៌មាន ។
- ទទួលខុសត្រូវការងារ សំណុំលិខិតឯកសារ លិខិតបទដ្ឋានច្បាប់ ឯកសារសំងាត់ ការងារទំនាក់ទំនងរដ្ឋបាលគ្រប់ផ្នែក ការតំកល់ឯកសារ ការងារសន្តិសុខ សណ្ដាប់ធ្នាប់ និងអនាម័យ ។
- គ្រប់គ្រងមន្ត្រី បុគ្គលិក និយោជិក និងអភិវឌ្ឍន៍ធនធានមនុស្ស ដោះស្រាយប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភផ្សេងៗ ដែលរាជរដ្ឋាភិបាលកំណត់ឲ្យមន្ត្រីបុគ្គលិកនិយោជិកទាំងនោះ ។
- រៀបចំគំរោងថវិកា គំរោងសំភារៈ និងមធ្យោបាយការងារ ។
- ទទួលខុសត្រូវចំពោះមុខអគ្គលេខាធិការ និងភ្នាក់ងារហិរញ្ញវត្ថុ នៃអង្គការផ្ដល់ជំនួយនានាក្នុងការប្រើប្រាស់ថវិកា ។
- គ្រប់គ្រងអចលនទ្រព្យ ចលនទ្រព្យ ទឹក ភ្លើង របស់អគ្គលេខាធិការដ្ឋាន ។

- ទទួលខុសត្រូវការប្រើប្រាស់ និងការថែទាំកុំព្យូទ័រក្នុងអគ្គលេខាធិការដ្ឋាន ។

**៨.៣ នាយកដ្ឋានផែនការ :**

- ទទួលខុសត្រូវក្នុងការប្រមូលផ្តុំ ចងក្រងស្ថិតិ នៃការសិក្សាទាំងឡាយក្នុងប្រទេស និងក្នុងតំបន់អាងទន្លេមេគង្គ ពីធនធានទឹក និងធនធានដទៃទៀត ដែលពាក់ព័ន្ធ ដើម្បីរៀបចំយុទ្ធសាស្ត្រផែនការ និងគោលនយោបាយអភិវឌ្ឍន៍រយៈពេលខ្លី មធ្យម វែង ស្នើជូនគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជាសម្រេច ។
- ធ្វើផែនការ និងទទួលខុសត្រូវលើការបណ្តុះបណ្តាល ដើម្បីអភិវឌ្ឍន៍ធនធានមនុស្សរយៈពេលខ្លី មធ្យម វែង ។
- សិក្សាស្រាវជ្រាវ រៀបចំ ណែនាំ តាមដានអនុវត្តគោលនយោបាយគោលការណ៍ជាយុទ្ធសាស្ត្រជាក់ស្តែង បទដ្ឋានគតិវិធីអភិវឌ្ឍន៍ធនធានទឹក និងធនធានដទៃទៀត ដែលពាក់ព័ន្ធក្នុងតំបន់ទន្លេមេគង្គ ។
- ស្រាវជ្រាវ និងចងក្រងបញ្ជីគោលការណ៍បទដ្ឋានគោល សំរាប់តាមដានរាល់កិច្ចការពារធនធានទឹក និងធនធានដទៃទៀត ដែលពាក់ព័ន្ធក្នុងតំបន់ទន្លេមេគង្គ ក្នុងក្របខ័ណ្ឌទាំងប្រទេស ។
- ជំនួយការឲ្យអគ្គលេខាធិការដ្ឋានក្នុងកិច្ចសហការជាមួយបណ្តាក្រសួង និង ស្ថាប័នដទៃទៀតដែលពាក់ព័ន្ធ និងធ្វើការទាក់ទងសហប្រតិបត្តិការអន្តរជាតិក្នុងក្របខ័ណ្ឌទន្លេមេគង្គ ។
- ទទួលខុសត្រូវក្នុងការប្រមូលផ្តុំ សំណើគម្រោងការបច្ចេកទេស ដែលពាក់ព័ន្ធទៅលើធនធានទឹក និងធនធានដទៃទៀត ដែលពាក់ព័ន្ធ ។

**៨.៤ នាយកដ្ឋានបណ្ណាគំពេខ :**

- ប្រមូល ត្រងព័ត៌មាន និងមូលដ្ឋានទិន្នន័យពាក់ព័ន្ធធនធានទឹក និងធនធានដទៃទៀត ដែលពាក់ព័ន្ធក្នុងអាងទន្លេមេគង្គ ។
- រៀបចំគ្រប់គ្រងបញ្ជីឯកសារដែលមិនទាន់បង្កើតផែនទី ។
- សិក្សាស្រាវជ្រាវ និងរៀបចំផែនទីអភិវឌ្ឍន៍ទន្លេមេគង្គ ។
- សិក្សាស្រាវជ្រាវផ្លូវប្រព័ន្ធព័ត៌មានភូមិសាស្ត្រ ។
- សិក្សាស្រាវជ្រាវ និងរៀបចំអភិវឌ្ឍន៍ផ្នែកថាមពលវារីអគ្គិសនី ។
- សិក្សាស្រាវជ្រាវ គ្រប់គ្រង និងអភិវឌ្ឍន៍ផ្នែកកសិកម្ម ក្នុងក្របខ័ណ្ឌអាងទន្លេមេគង្គ ។
- សិក្សាពីអភិវឌ្ឍន៍ផ្នែកទេសចរណ៍ ក្នុងក្របខ័ណ្ឌអាងទន្លេមេគង្គ ។
- សិក្សាស្រាវជ្រាវ និងវាយតម្លៃលើផលប៉ះពាល់ផ្នែកបរិស្ថាន ក្នុងការប្រើប្រាស់ធនធានទឹក និងធនធានដទៃទៀត ដែលពាក់ព័ន្ធនៃអាងទន្លេមេគង្គ ។

- អនុវត្តការងារគ្រប់គ្រង ត្រួតពិនិត្យ និងរាយការណ៍ពីសកម្មភាពការងារ ជំរាបជូនអគ្គលេខាធិការដ្ឋាន ។
- ជំនួយការឲ្យអគ្គលេខាធិការដ្ឋាន ក្នុងកិច្ចសហការជាមួយបណ្តាស្ថាប័នពាក់ព័ន្ធ និង ធ្វើសហប្រតិបត្តិការអន្តរជាតិ ។

មាត្រា ៩ .- ក្របខ័ណ្ឌមន្ត្រីរាជការ បុគ្គលិករបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ត្រូវកំណត់ដោយរាជរដ្ឋាភិបាល ។

មាត្រា ១០.- គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា មានសិទ្ធិបង្កើតគណនេយ្យមួយ និងប្រើប្រាស់ត្រាដោយឡែករបស់ខ្លួន ។

មាត្រា ១១.- ក្នុងរយៈពេល បីខែ គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ត្រូវកោះប្រជុំសាមញ្ញម្តងយ៉ាងតិច ។

មាត្រា ១២.- ក្នុងរយៈពេល ២សប្តាហ៍ គណៈកម្មការប្រតិបត្តិ នៃគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ត្រូវកោះប្រជុំសាមញ្ញម្តងយ៉ាងតិច ។

មាត្រា ១៣.- ក្នុងករណីចាំបាច់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា អាចកោះប្រជុំវិសាមញ្ញ :
- គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា
- គណៈកម្មការប្រតិបត្តិ ។

មាត្រា ១៤.- គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា មានសិទ្ធិអញ្ជើញប្រធានស្ថាប័នផ្សេងៗ ឬ តំណាង ដើម្បីចូលរួមប្រជុំគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ឬប្រជុំគណៈកម្មការប្រតិបត្តិ ។

## ជំពូក ៣
## អវសានបញ្ញត្តិ

មាត្រា ១៥.- ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំពោះ បណ្តានាយកដ្ឋានត្រូវកំណត់ដោយប្រកាសរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ។

មាត្រា ១៦.- បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ១៧.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ បណ្តាក្រសួង និងខេត្ត-ក្រុង ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាម ភារកិច្ចរៀងៗខ្លួន ។

មាត្រា ១៨.- អនុក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

★★★

## អង្គការលេខ
## របស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា



# អនុក្រឹត្យលេខ ១៦ អនក្រ.តត

## ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ អនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៨ ស្តីពីការបង្កើតអង្គភាពទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសេចក្តីត្រូវការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

## សំរេច

**មាត្រា ១ .-** តែងតាំងឯកឧត្តមឧត្តមសេនីយ៍ទោ **ឆេង មុនិន្ទ** ជាជំនួយការសម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកកិច្ចការកងរាជអាវុធហត្ថលើផ្ទៃប្រទេស មានឋានៈស្មើ អគ្គនាយក ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

***

# អនុក្រឹត្យលេខ ១៧ អនក្រ.តត

## ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល តំណាងភាគីរដ្ឋ នៃក្រុមហ៊ុនចំរុះសហគ្រាសឱសថកម្ពុជា "ស.ឱ.ក"

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីលក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**សំរេច**

**មាត្រា ១ .-** តែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលតំណាងរាជរដ្ឋ នៃក្រុមហ៊ុនចំរុះសហគ្រាសឱសថកម្ពុជា "ស.ឱ.ក" ដែលមានរាយនាមដូចខាងក្រោម ៖

១- លោក ពៅ ធុនសីហា អនុប្រធានរោងចក្រផលិតឱសថកម្ពុជាក្រសួងសុខាភិបាល សមាជិក

២- លោក ឃុន សារឹម អនុប្រធានរោងចក្រផលិតឱសថកម្ពុជា ក្រសួងសុខាភិបាល សមាជិក

៣- លោក សាន់ សារេ អនុប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

**មាត្រា ២ .-** ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង និងស្ថាប័នពាក់ព័ន្ធ ក្រុមហ៊ុន ROCHENTECH Co., LTD និងសាមីខ្លួន ដែលមានចែងនៅក្នុងមាត្រា ១ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ១៨ អនក្រ.តត

## ស្ដីពីការតែងតាំងមន្ត្រីរាជការ

* * *

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

**សំរេច**

មាត្រា ១ .- ផ្លាស់លោក សុខ សាធ បច្ចុប្បន្នទីប្រឹក្សាស្ថានទូត នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋប្រជាមានិតចិន ឲ្យចូលមកបំរើការងារក្នុងប្រទេសវិញ ដោយចប់អាណត្តិ ។

មាត្រា ២ .- បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ .- ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

***

## អនុក្រឹត្យលេខ ១៩ អនក្រ.តត

## ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

**សំរេច**

មាត្រា ១ .- តែងតាំងលោក អ៊ុក ស៊ីផុន បច្ចុប្បន្នអនុប្រធាននាយកដ្ឋានបុគ្គលិក នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាទីប្រឹក្សាស្ថានទូត នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសជប៉ុន ។

**មាត្រា ២ .-** បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ .-** ទីស្ដីការគណៈរដ្ឋមន្ត្រី ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ២០ អនក្រ.តត

## ស្ដីពីការតែងតាំងមន្ត្រីរាជការ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

## សំរេច

**មាត្រា ១ .-** តែងតាំងលោក ឆូច សែ បច្ចុប្បន្នអនុប្រធាននាយកដ្ឋានរដ្ឋបាល នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាទីប្រឹក្សាស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ។

**មាត្រា ២ .-** បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ .-** ទីស្ដីការគណៈរដ្ឋមន្ត្រី ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

# អនុក្រឹត្យលេខ ២១ អនក្រ.តត
## ស្ដីពីការតែងតាំងមន្ត្រីរាជការ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

## សំរេច

**មាត្រា ១ .-** តែងតាំងលោក តាន់ ខុនឃោន បច្ចុប្បន្នអនុប្រធាននាយកដ្ឋានអឺរ៉ុប នៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាទីប្រឹក្សាស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំសហរដ្ឋអាមេរិក ។

**មាត្រា ២ .-** បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ .-** ទីស្ដីការគណៈរដ្ឋមន្ត្រី ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

***

# អនុក្រឹត្យលេខ ២២ អនក្រ.តត
## ស្ដីពីការតែងតាំងមន្ត្រីរាជការ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

**សំរេច**

មាត្រា ១ .- តែងតាំងលោក នុន ជីវ័ន្ត បច្ចុប្បន្នអនុប្រធាននាយកដ្ឋាននៃអគ្គនាយកដ្ឋានអាស៊ាន ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាទីប្រឹក្សាស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋឥណ្ឌូណេស៊ី ។

មាត្រា ២ .- បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ .- ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ២៣ អនក្រ.តត

## ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

**សំរេច**

មាត្រា ១ .- តែងតាំងលោក កៅ សិទ្ធ បច្ចុប្បន្នអនុប្រធាននាយកដ្ឋានអាស៊ីប៉ាស៊ីហ្វិកនៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាទីប្រឹក្សាស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋប្រជាមានិតចិន ។

មាត្រា ២ .- បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ .- ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ២៨ អនក្រ.តត
## ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

## សំរេច

មាត្រា ១ .- តែងតាំងលោក សួន សាលីន បច្ចុប្បន្នទីប្រឹក្សាស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋបារាំង ជាទីប្រឹក្សាស្ថានតំណាងអចិន្ត្រៃយ៍ នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំយូណេស្កូ ។

មាត្រា ២ .- បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ .- ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ២៥ អនក្រ.តត
## ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

## សំរេច

មាត្រា ១ .- តែងតាំងលោក ឡុង ឌុល បច្ចុប្បន្នមន្ត្រីថ្នាក់ប្រធាននាយកដ្ឋាន ជាប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ។

មាត្រា ២ .- បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ .- ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

***

## អនុក្រឹត្យលេខ ២៦ អនក្រ.តត
## ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

**សំរេច**

មាត្រា ១ .- តែងតាំងលោក **សោត ទើត** បច្ចុប្បន្នអនុប្រធាននាយកដ្ឋានព័ត៌មាន និងឯកសារ ជាប្រធាននាយកដ្ឋានអង្គការអន្តរជាតិ នៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ។

មាត្រា ២ .- បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ .- ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

★★★

**អនុក្រឹត្យលេខ ២៧ អនក្រ.តត**

**ស្តីពីការតែងតាំងមន្ត្រីរាជការ**

* * *

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

**សំរេច**

មាត្រា ១ .- តែងតាំងលោក **ខ្ញុំ គុសលៈ** ជាទីប្រឹក្សារបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

**មាត្រា ២ .-** បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ .-** ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ, ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

***

## អនុក្រឹត្យលេខ ២៨ អនក្រ.តត

## ស្តីពីការតែងតាំង ផ្លាស់ប្តូរមុខងារ និងតំឡើងឋានន្តរសក្តិ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ

* * *

## រាជរដ្ឋាភិបាល

***

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការកែសម្រួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងអគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/២២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការតែងតាំងអគ្គបញ្ជាការនៃកងយោធពលខេមរភូមិន្ទ
- តាមសំណើរបស់អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ

## សំរេច

**មាត្រា ១ .-** ត្រូវបានតែងតាំង ផ្លាស់ប្តូរមុខងារ និងតំឡើងឋានន្តរសក្តិនាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម ៖

១- វរសេនីយ៍ឯក **ពៅ សុខា** បច្ចុប្បន្នជានាយការិយាល័យកាំភ្លើងធំកងទ័ពជើងគោក

២- វរសេនីយ៍ទោ **សុខ ប៊ុន** បច្ចុប្បន្នជានាយការិយាល័យការពារអាកាសកងទ័ពជើងគោក និងជាវរសេនីយ៍ឯក

៣- វរសេនីយ៍ទោ អ៊ុក គោសា បច្ចុប្បន្នជានាយការិយាល័យអភិវឌ្ឍន៍កងទ័ពជើងគោក និងជាវរសេនីយ៍ឯក

៤- វរសេនីយ៍ទោ កែវ ម៉ន បច្ចុប្បន្នជានាយការិយាល័យបញ្ជូនសារកងទ័ពជើងគោក និងជាវរសេនីយ៍ឯក

៥- វរសេនីយ៍ទោ នូ ចន្ថា បច្ចុប្បន្នជានាយការិយាល័យសុខាភិបាលកងទ័ពជើងគោកនិងជាវរសេនីយ៍ឯក

៦- វរសេនីយ៍ទោ ចាប សំពិង បច្ចុប្បន្នជានាយការិយាល័យហិរញ្ញវត្ថុកងទ័ពជើងគោក និងជាវរសេនីយ៍ឯក

៧- វរសេនីយ៍ទោ សូ សារិន បច្ចុប្បន្នជានាយការិយាល័យបច្ចេកទេសកងទ័ពជើងគោក និងជាវរសេនីយ៍ឯក

៨- វរសេនីយ៍ទោ នង សំអឿល បច្ចុប្បន្នជានាយការិយាល័យភ័ស្តុភារកងទ័ពជើងគោក និងជាវរសេនីយ៍ឯក

៩- វរសេនីយ៍ឯក កែវ ចណ្ណដេត បច្ចុប្បន្នជានាយសេនាធិការរង កងទ័ពជើងអាកាស

១០- វរសេនីយ៍ឯក ហែន ឆារ៉ាត់ បច្ចុប្បន្នជានាយសេនាធិការរង កងទ័ពជើងអាកាស

១១- វរសេនីយ៍ឯក ស៊ុន ណារ៉ា បច្ចុប្បន្នជានាយសេនាធិការរង កងទ័ពជើងអាកាស

១២- វរសេនីយ៍ទោ ហែម សារិទ្ធ បច្ចុប្បន្នជានាយសេនាធិការរង កងទ័ពជើងអាកាស និងជា វរសេនីយ៍ឯក

១៣- វរសេនីយ៍ទោ ម៉ៅ សេខ បច្ចុប្បន្នជានាយសេនាធិការរង កងទ័ពជើងអាកាស និងជា វរសេនីយ៍ឯក

១៤- វរសេនីយ៍ទោ គីម គន្ធា បច្ចុប្បន្នជានាយសេនាធិការរង កងទ័ពជើងអាកាស និងជាមេបញ្ជាការព្រលានយន្តហោះយោធា ពោធិចិនតុង និងជា វរសេនីយ៍ឯក

១៥- វរនាវីឯក គីម ស៊ុនថា បច្ចុប្បន្នជានាយសេនាធិការរង កងទ័ពជើងទឹក

១៦- វរនាវីឯក ទ៉ាន់ ប៊ុនលាង បច្ចុប្បន្នជានាយសេនាធិការរង កងទ័ពជើងទឹក

១៧- វរនាវីឯក ស្រេង សារី បច្ចុប្បន្នជានាយសេនាធិការរង កងទ័ពជើងទឹក

១៨- វរនាវីទោ យស សម្បត្តិ បច្ចុប្បន្នជានាយសេនាធិការរង កងទ័ពជើងទឹក និងជា វរនាវីឯក

១៩- វរសេនីយ៍ឯក ចាន់ លំផាត់ បច្ចុប្បន្នជានាយសេនាធិការរង យោធភូមិភាគទី ២

២០- វរសេនីយ៍ឯក យឹម យ៉ាន បច្ចុប្បន្នជាមេបញ្ជាការតំបន់ប្រតិបត្តិការសឹករង ក្រចេះ

២១- វរសេនីយ៍ទោ ហ៊ុ ហ៊ិន បច្ចុប្បន្នជាមេបញ្ជាការតំបន់ប្រតិបត្តិការសឹករងព្រៃវែង និងជា វរសេនីយ៍ឯក

២២- វរសេនីយ៍ទោ ខាំ ស៊ុក បច្ចុប្បន្នជាមេបញ្ជាការតំបន់ប្រតិបត្តិការសឹករងស្ទឹងត្រែង

និងជា [illegible]

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ អគ្គនាយកនគរបាលជាតិ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ២៩ អនក្រ.តត

## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ អនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៨ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណូមពរការងារចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

## សំរេច

មាត្រា ១ .- តែងតាំងជំនួយការឯកឧត្តម គន់ គីម ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជាចំនួន ០២រូប មាននាមៈតៅ ព្រមានរាយនាមខាងក្រោម ៖

១- លោក សោម សុទ្ធារី

២- លោក ត្រាំ ជ៉ុំវិណា

មាត្រា ២ .- បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ៣០ អនក្រ.តត

## ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

## សម្រេច

**មាត្រា ១ .-** តែងតាំងលោក **គាន់ គុំ** បច្ចុប្បន្នលេខាទី១ ស្ថានទូត នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសម៉ាឡេស៊ី ជាទីប្រឹក្សាស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសម៉ាឡេស៊ី។

**មាត្រា ២ .-** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ .-** ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងឡាយ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ៣១ អនក្រ.តត
## ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

### សំរេច

មាត្រា ១ .- តែងតាំងលោក អ៊ឹង នាស៊ាម ជាទីប្រឹក្សាស្ថានទូត នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំរាជាណាចក្រថៃឡង់ ។

មាត្រា ២ .- បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ .- ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងឡាយ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ៣២ អនក្រ.តត
## ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

**សំរេច**

មាត្រា ១ .- តែងតាំងលោកបណ្ឌិត **ឆង់ ចេដ្ឋា** ជាអគ្គទីប្រឹក្សាស្ថានបេសកកម្មអចិន្ត្រៃយ៍ នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំអង្គការសហប្រជាជាតិ ។

មាត្រា ២ .- បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ .- ទីស្ដីការគណៈរដ្ឋមន្ត្រី ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធទាំងឡាយ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

* * *

## អនុក្រឹត្យលេខ ៣៣ អនក្រ.តត
## ស្ដីពីការតែងតាំងមន្ត្រីរាជការ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

**សំរេច**

មាត្រា ១ .- តែងតាំងលោក **ជឹង ម៉ុនថេង** បច្ចុប្បន្ន អនុប្រធាននាយកដ្ឋានអាមេរិក ជាអគ្គទីប្រឹក្សាស្ថានទូត នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំរាជាណាចក្រថៃឡង់ ។

មាត្រា ២ .- បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ .-** ទីស្ដីការគណៈរដ្ឋមន្ត្រី ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធទាំងឡាយ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

★★★

## ២.សេចក្ដីសំរេច

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

### សេចក្ដីសំរេចលេខ ០៩ សសរ

### ស្ដីពីការផ្ទេរសារកិច្ច

* * *

### រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណូមពរការងារចាំបាច់របស់រាជរដ្ឋាភិបាល

### សំរេច

**ប្រការ ១ :** ផ្ទេរសិទ្ធិជូនឯកឧត្ដម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្ដីទី នៃរាជរដ្ឋាភិបាល ជំនួសសម្ដេចនាយករដ្ឋមន្ត្រី ដែលត្រូវអញ្ជើញទៅបំពេញទស្សនកិច្ចជាផ្លូវការនៅប្រទេសម៉ាឡេស៊ី ចាប់ពីថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ១៩៩៩ រហូតដល់សម្ដេចនាយករដ្ឋមន្ត្រី អញ្ជើញវិលនិវត្តមកកាន់មាតុប្រទេសវិញ ។

**ប្រការ ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន ខេត្ត-ក្រុង និងឯកឧត្ដម ស ខេង ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសំរេចនេះ ឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

នាយករដ្ឋមន្ត្រីទី១

ហត្ថលេខានិងត្រា

ហ៊ុន សែន

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

## សេចក្តីសម្រេចលេខ ១០ សសរ

## ស្តីពីការផ្ទេរភារកិច្ច

* * *

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

ប្រការ ១ : ផ្ទេរសិទ្ធិជូនឯកឧត្តម ឆាយ ថន រដ្ឋមន្ត្រីក្រសួងផែនការ ជារដ្ឋមន្ត្រីស្តីទីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ពីឯកឧត្តម អ៊ឹម ឈុនលឹម ដែលត្រូវអញ្ជើញទៅទស្សនកិច្ចជាផ្លូវការ នៅសាធារណរដ្ឋប្រជាមានិតចិន ចាប់ពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ១៩៩៩ រហូតដល់ឯកឧត្តម អ៊ឹម ឈុនលឹម អញ្ជើញវិលត្រឡប់មកកាន់មាតុប្រទេសវិញ ។

ប្រការ ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន និងឯកឧត្តម ឆាយ ថន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

***

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

## សេចក្ដីសំរេចលេខ ១១ សសរ

## ស្ដីពីការអនុញ្ញាតជាគោលការណ៍ឲ្យក្រុមហ៊ុន AZ Distribution Co., Ltd អភិវឌ្ឍន៍ និង ពង្រីកបន្ថែមនូវប្រព័ន្ធ និង សេវាទូរគមនាគមន៍ ជាតិទូទាំងព្រះរាជាណាចក្រកម្ពុជា

* * *

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញ ច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១០៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨
- ក្នុងគោលដៅអនុវត្តគោលនយោបាយលើកទឹកចិត្តរបស់រាជរដ្ឋាភិបាល ចំពោះក្រុមហ៊ុនក្នុងស្រុក
- យោងលើសេចក្ដីសំរេចលេខ ១៧ សសរ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ១៩៩៨
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៩៩

## សំរេច

**ប្រការ ១ :** អនុញ្ញាតឲ្យក្រុមហ៊ុន AZ Distribution Co., Ltd បានរាយបណ្ដាញកាប្លិ៍អុបទិច (Fibre Optic Cable) ទូទាំងព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ២ :** អនុញ្ញាតឲ្យមានតែបណ្ដាញកាប្លិ៍អុបទិចតែមួយ ដែលក្រុមហ៊ុន AZ Distribution Co., Ltd វិនិយោគក្នុងរយៈពេល ២៥ឆ្នាំ ។

**ប្រការ ៣ :** អនុញ្ញាតឲ្យក្រុមហ៊ុន AZ Distribution Co., Ltd ផ្ដល់បណ្ដាញទូរស័ព្ទ និងសេវាទិន្នន័យតាមបណ្ដាខេត្ត-ក្រុង និងជនបទ ដូចបានរាយលំអិតនៅក្នុងគំរោងមេ (Master Plan) ក្នុងរយៈពេល ៣៥ឆ្នាំ គិតចាប់ពីឆ្នាំ ដែលប្រើប្រាស់ជាផ្លូវការ (Operational Year) ។

**ប្រការ ៤ :** អនុញ្ញាតឲ្យក្រុមហ៊ុន AZ Distribution Co., Ltd បានបន្តនិរន្តភាព ចំពោះសេវាច្រកចេញអន្តរជាតិ ក្រោយពេលផុតកិច្ចសន្យារបស់ TELSTRA នៅឆ្នាំ ២០០០ ។

**ប្រការ ៥ :** ក្រុមហ៊ុនត្រូវពង្រីកនូវសមត្ថភាពរបស់ច្រកចេញអន្តរជាតិ ដោយភ្ជាប់ផ្ទាល់ជាមួយកាប្លិ៍ក្រោមសមុទ្រ ឬ ជាមួយប្រព័ន្ធទំនើបផ្សេងៗទៀត ។

**ប្រការ ៦ :** ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ត្រូវពិភាក្សាផ្ទាល់ស្តែងជាមួយក្រុមហ៊ុន បន្ថែមលើគោលការណ៍ដែលបានកំណត់ខាងលើ ដើម្បីអោយការចុះហត្ថលេខាលើកិច្ចព្រមព្រៀងឲ្យបានឆាប់ ហើយដំណើរការអនុវត្តគំរោងនេះ ។

**ប្រការ ៧ :** ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងដែលពាក់ព័ន្ធ ក្រុមហ៊ុន AZ Distribution Co., Ltd មានភារកិច្ចអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

★★★

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

## សេចក្តីសំរេចលេខ ១២ សសរ

## ស្តីពីការផ្ទេរភារកិច្ច

* * *

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណូមពរការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១ :** ផ្ទេរសិទ្ធិជូនឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាល ជំនួសសម្តេចនាយករដ្ឋមន្ត្រី ដែលត្រូវអញ្ជើញទៅបំពេញទស្សនកិច្ចជាផ្លូវការ នៅសាធារណរដ្ឋប្រជាមានិតចិន ចាប់ពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ ១៩៩៩ រហូតដល់សម្តេចនាយករដ្ឋមន្ត្រី អញ្ជើញវិលនិវត្តមកកាន់មាតុប្រទេសវិញ ។

ប្រការ ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន ខេត្ត-ក្រុង និងមេកឧត្តម ស ខេខ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

★★★

# III- ការងារបណ្ណាក្រសួង

## ១.ទីស្តីការរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

## ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

**ប្រកាសលេខ ៣៦០ MOC/M99**

**ស្តីពីបង្កើតគណៈកម្មការគ្រប់គ្រងកូតា សំរាប់ការនាំចេញវាយនភ័ណ្ឌ និងផលិតផលវាយនភ័ណ្ឌដែលជាកម្មវត្ថុ នៃការកំណត់បរិមាណ ដោយសហរដ្ឋអាមេរិក**

****

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦/អនុក្រ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពី ការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញ អនុក្រឹត្យលេខ ៥៤ អនក្រ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅនៃក្រសួងពាណិជ្ជកម្ម
- យោងតាមកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញវាយនភ័ណ្ឌ និងផលិតផលវាយនភ័ណ្ឌ ធ្វើពីកប្បាស រោមចៀម សរសៃសិប្បនិម្មិតដោយដៃមនុស្ស សរសៃរុក្ខជាតិគ្មានជាតិកប្បាស

និងសេចក្តីព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលអាមេរិក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩៩

- យោងសេចក្តីសម្រេចអង្គប្រជុំគណៈរដ្ឋមន្ត្រី នៅថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៩៩
- បានឃើញ ការចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ ១ :** បង្កើតប្រព័ន្ធគ្រប់គ្រងកូតាអេឡិចត្រូនិច (EQMS) ដើម្បីគ្រប់គ្រងឲ្យមានសណ្តាប់ធ្នាប់ សមស្រប តម្លាភាពជាមុន និងមានគណនេយ្យភាពក្នុងការបែងចែកកូតា សម្រាប់ការនាំចេញគ្រប់ប្រភេទ (Categories) វាយនភណ្ឌ និងផលិតផលវាយនភណ្ឌកម្ពុជា ដែលជាកម្មវត្ថុ នៃការកំណត់បរិមាណ ដោយរដ្ឋាភិបាលសហរដ្ឋអាមេរិក ។

**ប្រការ ២ :** បង្កើតគណៈកម្មការគ្រប់គ្រងកូតានាំចេញ (EQMS) ដែលរួមមានសមាសភាពដូចតទៅ ៖

| | | |
|---|---|---|
| ១- ឯកឧត្តម ចម ប្រសិទ្ធ | រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | ប្រធាន |
| ២- ឯកឧត្តម ឌិត ម៉ុង | អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | អនុប្រធានអចិន្ត្រៃយ៍ |
| ៣- ឯកឧត្តម ហ៊ុល លឹម | អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល | អនុប្រធាន |
| ៤- ឯកឧត្តម សយ ស៊ីផុន | អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា | អនុប្រធាន |
| ៥- ឯកឧត្តម ម៉ៅ ថូរ៉ា | អគ្គនាយកបច្ចេកទេសក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៦- លោក ស៊ុត សារា | ប្រធាននាយកដ្ឋានកាំកុងត្រូលក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៧- លោក ឈាំង ស៊ីផា | ប្រធាននាយកដ្ឋានអធិការកិច្ចក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា | សមាជិក |
| ៨- លោក ចាន់ ណារិទ្ធ | អនុប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៩- លោក ម៉ែន សុទិជាតិ | អនុប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម | លេខាគណៈកម្មការ |
| ១០- លោក សាត សមុទ្រ | អនុប្រធាននាយកដ្ឋានបច្ចេកទេសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ១១- លោក ចាន់ ស៊ីអៀង | ប្រធានសមាគមកាត់ដេរកម្ពុជា | សមាជិក |
| ១២- លោក លី ថៃ ឃីត | អនុប្រធានសមាគមកាត់ដេរកម្ពុជា | សមាជិក |
| ១៣- លោក អាល់ប៊ឺត អ៊ីង | អនុប្រធានសមាគមកាត់ដេរកម្ពុជា | សមាជិក |
| ១៤- លោក រ៉ូហ្សី តាន់ | អគ្គលេខាធិការសមាគមកាត់ដេរកម្ពុជា | សមាជិក |

**ប្រការ ៣ :** គណៈកម្មការគ្រប់គ្រងកូតានាំចេញនេះ នឹងជួបប្រជុំរៀងរាល់ថ្ងៃច័ន្ទ វេលាម៉ោង ៨:០០ ព្រឹក នៅទីស្តីការក្រសួងពាណិជ្ជកម្ម ដើម្បីដោះស្រាយរាល់បញ្ហាទាក់ទងនឹងការបែងចែកកូតា ដូចមានចែងក្នុងប្រការ ៤ ខាងក្រោម ៖

គណៈកម្មការគ្រប់គ្រងកូតានាំចេញនេះនឹងធ្វើការត្រួតពិនិត្យ ឬធ្វើទស្សនៈកិច្ចរោងចក្រកាត់ដេរសំលៀកបំពាក់ ដើម្បីធ្វើការពិនិត្យ និងផ្ទៀងផ្ទាត់ :

- ឯកសារអាជីវកម្មនានា ដូចជា ប័ណ្ណបញ្ជាទិញរបស់អតិថិជនអាមេរិក ប័ណ្ណឥណទាន កិច្ចសន្យាជួលផលិត ដែលបានទទួលការអនុញ្ញាតត្រឹមត្រូវ ។ល។
- ព័ត៌មានអំពីផលិតកម្ម : ចំនួនផលិតផល វិក្កយបត្រនៃការទិញវត្ថុធាតុដើម ចំនួនម៉ាស៊ីន តារាងបើកប្រាក់បៀវត្សប្រចាំសប្តាហ៍ ឬប្រចាំខែ ចំនួនកម្មករ ចំនួនថ្ងៃធ្វើការងារ ម៉ោងបន្ថែម កំណត់ត្រាអំពីការកាត់ ដេរ វេចខ្ចប់ ទិន្នផល សក្តិផលិតកម្ម ។ល។
- ឯកសារនាំចេញ : ប្រតិវេទន៍នាំចេញរបស់គយ របាយការណ៍ត្រួតពិនិត្យរបស់កាំកុងត្រូល អញ្ញត្តិប័ណ្ណដឹកជញ្ជូនផ្លូវទឹក ឬ ផ្លូវអាកាស ប័ណ្ណដឹកជញ្ជូនផ្លូវគោក វិក្កយបត្រពាណិជ្ជកម្ម ។ល។
- ឯកសារទាក់ទងនឹងបៀវត្ស តាមការទាមទារនៃការងារសវនកម្ម ។

គណៈកម្មការគ្រប់គ្រងកូតានាំចេញ នឹងរៀបចំជាប្រចាំនូវការដេញថ្លៃជាលក្ខណៈសំរាប់ការដេញថ្លៃប្រភេទកូតាដេញថ្លៃ ដូចមានចែងក្នុងប្រការ ៤ ខាងក្រោម ។

**ប្រការ ៤ :** ចាប់តាំងពីថ្ងៃទី០១ ខែមករា ឆ្នាំ១៩៩៩ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៩ ក្រសួងពាណិជ្ជកម្ម នឹងចាត់ចេញនូវកូតាចំនួនប្រាំ (០៥)ប្រភេទ ចំពោះកូតានាំចេញទាំងអស់សំរាប់ការនាំចេញវាយនភ័ណ្ឌ និងផលិតផលវាយនភ័ណ្ឌទៅកាន់សហរដ្ឋអាមេរិក ។

១- <u>កូតាមូលដ្ឋាន (Fundamental Quota "FQ")</u> : គឺជាកូតាដែលផ្តល់ជូន សំរាប់បំពេញសេចក្តីត្រូវការនៃរោងផលិតកម្ម និងផ្អែកលើស្ថេរភាពទីផ្សាររបស់បណ្តាក្រុមហ៊ុនកាត់-ដេរសំលៀកបំពាក់ទាំងឡាយ ។ កូតានេះ នឹងត្រូវបែងចែកជាពីរលើកក្នុងឆ្នាំសារពើពន្ធ ១៩៩៩ ផ្អែកលើការអនុវត្តន៍កន្លងមកក្នុងឆ្នាំសារពើពន្ធ ១៩៩៨ សមត្ថភាពផលិតកម្ម កំរិតភាគរយខ្ពស់នៃការប្រើប្រាស់វត្ថុធាតុដើមក្នុងស្រុក និងកិច្ចសន្យាជាមួយអ្នកទិញអាមេរិក (លើកលែងតែការបែងចែកក្នុងឆមាសទី២ ដែលត្រូវផ្អែកផងដែរលើការអនុវត្តន៍បានត្រឹមត្រូវតាមបទដ្ឋានការងារ) :

១.១ <u>កូតាមូលដ្ឋានឆមាសទី១ (FQ 1)</u> : នឹងត្រូវបែងចែកភ្លាមៗ ដូចមានចែងក្នុងឧបសម្ព័ន្ធ $A_1$ និង $A_2$ ។

១.២ <u>កូតាមូលដ្ឋានឆមាសទី ២ (FQ 2)</u> : នឹងត្រូវបែងចែកក្នុងសប្តាហ៍ទី ១ នៃខែមេសា ឆ្នាំ១៩៩៩ ។ កូតាមូលដ្ឋានឆមាសទី ២ នេះអាចតិចជាង ឬ ច្រើនជាងកូតាមូលដ្ឋានឆមាសទី ១ ផ្អែកលើការអនុវត្តន៍របស់ក្រុមហ៊ុន និងការបំពេញបានត្រឹម

ត្រូវតាមច្បាប់ និងបទបញ្ញត្តិទាំងឡាយរបស់កម្ពុជា ក៏ដូចជាគោរពតាមលក្ខខណ្ឌទាំងឡាយ នៃកិច្ចព្រមព្រៀងខាងលើ ។

២- កូតាពិសេស (Special Quota "SQ") : គឺជាកូតាដែលត្រូវបែងចែកលើមូលដ្ឋាន នៃការពិនិត្យមើលករណីផ្សេងៗ សំរាប់ក្រុមហ៊ុនកាត់ដេរថ្មីទាំងឡាយ និងរោងចក្របច្ចុប្បន្ន ដែលមានការផ្សព្វផ្សាយតាមបញ្ហាពិសេស ក្នុងវិស័យកាត់ដេរ ។

៣- កូតាដេញថ្លៃ (Auctioned Quota "AQ") : គឺជាកូតាដែលនឹងត្រូវដេញថ្លៃជាប្រចាំដើម្បីបំពេញតម្រូវការជាបន្ទាន់របស់រោងចក្រក្រុមហ៊ុន ។

៤- រង្វាន់ (Reward Quota "RQ") : គឺជាកូតាដែលនឹងត្រូវផ្តល់ជារង្វាន់នៅក្នុងត្រីមាសទី១ នៃខែមករា ឆ្នាំ១៩៩៩ ចំពោះក្រុមហ៊ុនទាំងឡាយ ដែលកំពុងនាំចេញវាយនភ័ណ្ឌ និងផលិតផលវាយនភ័ណ្ឌ មានស្តង់ដារខ្ពស់ និង/ ឬបានបំពេញបានត្រឹមត្រូវទាំងស្រុងតាមច្បាប់ការងារកម្ពុជា ដោយផ្អែកទៅលើបទដ្ឋានការងារ ដែលបានការទទួលស្គាល់ជាអន្តរជាតិ ។

៥- កូតាកំណើន (Growth Quota "GQ") : កូតាដែលត្រូវបែងចែកជូនរោងចក្រ ដែលបានបើកដំណើរការនៅក្នុងឆ្នាំមុន ដោយផ្អែកលើមូលដ្ឋាន នៃសមាមាត្រកំណើនសំរាប់ប្រភេទសំលៀកបំពាក់នីមួយៗ ។

ប្រការ ៥ : គ្រប់ទាំងកំរិតកំណត់ដោយសន្ធិសញ្ញាលើសហរដ្ឋអាមេរិក សំរាប់ប្រភេទទាំងឡាយ នៃវាយនភ័ណ្ឌ និងផលិតផលវាយនភ័ណ្ឌ កូតានាំចេញទាំងអស់សំរាប់ប្រភេទនីមួយៗនឹងត្រូវបានគណនា ដូចខាងក្រោម :

- កូតាមូលដ្ឋានចំណាត់ទី១ (FQ1): ៥០%នៃការអនុវត្តន៍សរុបរបស់ឆ្នាំសារពើពន្ធ ១៩៩៨
- កូតាមូលដ្ឋានចំណាត់ទី២ (FQ2): ៥០%នៃការអនុវត្តន៍សរុបរបស់ឆ្នាំសារពើពន្ធ ១៩៩៨
- កូតាពិសេស (SQ) : ៧០% នៃ(បរិមាណកូតារបស់អាមេរិកសំរាប់ឆ្នាំសារពើពន្ធ ១៩៩៩ ដកការអនុវត្តន៍សរុបនៃឆ្នាំសារពើពន្ធឆ្នាំ ១៩៩៨) ។
- កូតាដេញថ្លៃ (AQ) : ៣០% នៃ(បរិមាណកូតារបស់អាមេរិកសំរាប់ឆ្នាំសារពើពន្ធ ១៩៩៩ ដកការអនុវត្តន៍សរុបនៃឆ្នាំសារពើពន្ធឆ្នាំ ១៩៩៨) បូក ១០% នៃការអនុវត្តន៍សរុបរបស់ឆ្នាំសារពើពន្ធ ១៩៩៨ ។
- កូតារង្វាន់ (RQ) : ១៥% នៃបរិមាណកូតារបស់អាមេរិកសំរាប់ឆ្នាំសារពើពន្ធ ២០០០ បូក ១០% នៃការអនុវត្តន៍សរុបរបស់ឆ្នាំសារពើពន្ធ ១៩៩៨ ។
- កូតាកំណើន (GQ) : ៦% នៃកំណើនលើសំលៀកបំពាក់ ដែលធ្វើពីកប្បាស ឬសរសៃសិប្បនិម្មិត ធ្វើដោយដៃមនុស្ស ឬ ១% នៃកំណើនលើសំលៀកបំពាក់ធ្វើពីរោមសត្វ ដោយផ្អែកលើមូលដ្ឋានកូតារបស់សហរដ្ឋអាមេរិកក្នុងឆ្នាំសារពើពន្ធ ១៩៩៩ ។

ចំនួនសម្ពាធអតិបរមាសម្រាប់ នៃការកំណត់តម្លៃកូតា ពិតអនុញ្ញាតនាំចេញសម្រាប់ B ។

ប្រការ ៦ : ចំពោះប្រភេទផលិតផលនានានៃវាយនភណ្ឌ ឬ ផលិតផលវាយនភណ្ឌ ដែលជាប់កូតាចំរៃ (EQMF) នៃការគ្រប់គ្រងកូតានាំចេញនឹងត្រូវបានគណនា តាមរបៀបការកំណត់តម្លៃគ្រប់ប្រភេទកូតាទាំងឡាយ ទោះជាមានការផ្លាស់ប្តូរតែប្រភេទកូតាតែមួយក្តី ។ តម្លៃនៃការគ្រប់គ្រងកូតានាំចេញ ដែលនឹងត្រូវកំណត់ក្នុងឆ្នាំសារពើពន្ធ ១៩៩៩ មានដូចតទៅ :

| | |
|---|---|
| ប្រភេទ ៣៣១/៦៣១ | ១.០០០ រៀល / ឡូតិ៍ |
| ប្រភេទ ៣៣៤/៦៣៤ | ២.០០០ រៀល / ឡូ |
| ប្រភេទ ៣៣៥/៦៣៥ | ២.០០០ រៀល / ឡូ |
| ប្រភេទ ៣៣៨/៣៣៩ | ៣.៥០០ រៀល / ឡូ |
| ប្រភេទ ៣៤០/៦៤០ | ៣.៥០០ រៀល / ឡូ |
| ប្រភេទ ៣៤៥ | ៥.០០០ រៀល / ឡូ |
| ប្រភេទ ៣៤៧/៣៤៨/៦៤៧/៦៤៨ | ៥.០០០ រៀល / ឡូ |
| ប្រភេទ ៣៥២/៦៥២ | ៣.៥០០ រៀល / ឡូ |
| ប្រភេទ ៤៣៨ | ៥.០០០ រៀល / ឡូ |
| ប្រភេទ ៤៤៥/៤៤៦ | ៥.០០០ រៀល / ឡូ |
| ប្រភេទ ៦៣៨/៦៣៩ | ៣.៥០០ រៀល / ឡូ |
| ប្រភេទ ៦៤៥/៦៤៦ | ៥.០០០ រៀល / ឡូ |

ចំពោះបណ្ដាប្រភេទដទៃទៀតដែលមិនជាប់កូតា ដោយគោលការណ៍ស្មើភាពនោះ នឹងមិនត្រូវបង់ចំរៃ (EQMF) ទេ ។

គ្រប់ការនាំចេញទាំងអស់ទៅកាន់ប្រទេសជាសមាជិក នឹងត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យនៃការចេញវិញ្ញាបនបត្រនាំចេញនៅលើវិក្កយបត្រពាណិជ្ជកម្ម ដោយក្រសួងពាណិជ្ជកម្ម ។ តម្លៃសេវា គឺស្មើ ចំនួន ១២០.០០០រៀល នឹងត្រូវកំណត់ចំពោះការចេញវិញ្ញាបនបត្រនីមួយៗ ។

ប្រការ ៧ : ការបង់តម្លៃគ្រប់គ្រងកូតានាំចេញ នឹងត្រូវធ្វើជាប្រាក់រៀល ដែលត្រូវបង់ជូនទៅបញ្ជរលេខា នៃក្រសួងពាណិជ្ជកម្ម ជាសាច់ប្រាក់ ឬមូលប្បទានប័ត្រ តាមជាប្រព័ន្ធដែលគណៈកម្មការគ្រប់គ្រងកូតានាំចេញ ។

គណៈកម្មការគ្រប់គ្រងកូតានាំចេញ នឹងបើកគណនីពិសេសមួយនៅធនាគារជាតិ ដែលតម្កល់ទុកនោះ ទុកសម្រាប់ប្រើប្រាស់ក្នុងការចំណាយតំរៃគ្រប់គ្រងកូតានាំចេញ ។

នៅពេលចុងក្រោយនៃឆ្នាំនីមួយៗ ប្រធាននៃគណៈកម្មការគ្រប់គ្រងកូតានាំចេញ នឹងផ្ទេរប្រាក់តម្លៃនៃការគ្រប់គ្រងកូតា ចំនួន ១០០% ដែលប្រមូលបានក្នុងឆ្នាំគ្រប់គ្រងនោះ ទៅក្នុងថវិកាជាតិ ដោយកាត់យកទុកចំនួន ៥០% សម្រាប់ប្រើប្រាស់ក្នុងគោលបំណងនានាទាំងឡាយ ដែលជាប្រយោជន៍ដល់ការអភិវឌ្ឍន៍ផលិតកម្មសំលៀកបំពាក់ និងការលើកស្ទួយការងារនៅកម្ពុជា ។

ប្រការ ៨ : ក្រុមហ៊ុនកាត់ដេរសំលៀកបំពាក់ទាំងឡាយ ដែលបានទទួលការអនុញ្ញាតត្រឹមត្រូវ ហើយបានចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម ព្រមទាំងចុះបញ្ជីនៅនាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ហើយដែលបានធ្វើការនាំចេញមុនថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៩៩ ជាមួយនឹងលិខិតបញ្ជាក់ប្រភពដើមត្រឹមត្រូវ ។ រោងចក្រទាំងឡាយណា ដែលមិនត្រូវបានបែងចែកកូតាសំរាប់ឆ្នាំការពិសោធ ១៩៩៩ នឹងត្រូវអនុញ្ញាតឲ្យដាក់ពាក្យសុំនេះកូតាពិសេស (SQ) និងកូតាបន្ថែម (AQ) ប៉ុណ្ណោះ ។ ការអនុវត្តន៍របស់រោងចក្រទាំងនេះក្នុងឆ្នាំការពិសោធ ឆ្នាំ ១៩៩៩ នឹងត្រូវបានយកមកពិចារណា សំរាប់ការដាក់ពាក្យសុំនេះប្រភេទកូតាដទៃទៀត ក្នុងឆ្នាំការពិសោធ ឆ្នាំ ២០០០ ។

ប្រការ ៩ : គណៈកម្មការគ្រប់គ្រងកូតានាំចេញ នឹងធ្វើការប្រកាសជាសាធារណៈឲ្យបានទៀងទាត់ ដែលនៅសល់ពីការប្រើប្រាស់ នូវបញ្ជីបរិមាណកូតាដែលនៅសល់តាមប្រភេទ (Category) កូតានីមួយៗ នៃរាល់សប្តាហ៍ និងតំណែងដែលសប្តាហ៍ទាំងឡាយ ។ គណៈកម្មការនឹងពិនិត្យមើលនូវតំរូវការជាក់ស្តែង សំរាប់ការដាក់ពាក្យស្នើសុំប្រភេទកូតាទាំងឡាយ ។

ប្រការ ១០ : ចំពោះប្រព័ន្ធចែកចាយកូតាសំរាប់រយៈពេលពីថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៨ រហូតដល់ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ដូចមានចែងក្នុងប្រកាសលេខ 114 MoC/M99 ចុះថ្ងៃទី១២ ខែមករា ឆ្នាំ១៩៩៩ របស់ក្រសួងពាណិជ្ជកម្មនឹងត្រូវជំនួសដោយកូតា ដែលមានចែងក្នុងប្រកាសនេះ ។

ប្រការ ១១ : ចាប់តាំងពីថ្ងៃទី០១ ខែមីនា ឆ្នាំ១៩៩៩ រាល់ប្រតិបត្តិការកិច្ចសន្យាម៉ៅការបន្ត (Sub Contracting) ពិសេសនឹងត្រូវអនុញ្ញាតឲ្យធ្វើបាន លុះត្រាតែមានការអនុម័តជាមុនពីក្រសួងពាណិជ្ជកម្ម និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ការអនុម័តនេះនឹងត្រូវផ្អែកលើលក្ខខណ្ឌដែលបានចែង គណៈកម្មការគ្រប់គ្រងកូតានាំចេញសំរាប់យកមកពិចារណាក្នុងការបែងចែកកូតានៅពេលបន្ទាប់ ។

ប្រការ ១២ : ចាប់ពីថ្ងៃទី០១ ខែមីនា ឆ្នាំ១៩៩៩ តទៅ ការនាំចូលនូវផលិតផលពាក់កណ្តាលសំរេចតាមកម្មវិធី OPA (Outward Processing Arrangement) នឹងមិនត្រូវបានអនុញ្ញាតទៀតទេ ចំពោះផលិតផលសំលៀកបំពាក់ប្រភេទណា ដែលស្ថិតនៅក្រោមការកំណត់កូតារបស់រដ្ឋាភិបាលអាមេរិក ដូចមានចែងក្នុងកិច្ចព្រមព្រៀងវាយនភណ្ឌ ។

**ប្រការ ១៣ :** នាយកខុទ្ទកាល័យ អគ្គនាយកបច្ចេកទេស ប្រធាននាយកដ្ឋានកាំកុងត្រូល ប្រធាននាយកប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម រាល់ផលិតករសំលៀកបំពាក់ និងអ្នកដែលមានរាយនាមក្នុងប្រការ ២ ត្រូវទទួលអនុវត្តនូវប្រកាសនេះ ។

**ប្រការ ១៤ :** បទបញ្ញត្តិទាំងឡាយណាពីមុនមករបស់ក្រសួងពាណិជ្ជកម្ម ដែលផ្ទុយពីប្រការនានានៃប្រកាសនេះ នឹងត្រូវចាត់ទុកជានិរាករណ៍ ។ ប្រកាសនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
ហត្ថលេខានិងត្រា
**ចម ប្រសិទ្ធ**

★★★

MINISTRY OF COMMERCE/EQMC

ANNEX A1

EXPORT QUOTAS ALLOCATION IN FY 1999

| Category | Apparel | Unit | FQ1 | FQ2 | 10%RQ | 10%AQ | 30%AQ | 70%SQ | 1999EQ |
|---|---|---|---|---|---|---|---|---|---|
| 331/631 | Gloves & Mittens | Dpr | 450,000 | 450,000 | 112,000 | 112,000 | 127,800 | 298,200 | 1,550,000 |
| 334/634 | Other M & B Coats | Doz | 34,000 | 34,000 | 8,000 | 8,000 | 25,800 | 60,200 | 170.000 |
| 335/635 | W & G Coats | Doz | 9,000 | 9,000 | 2,000 | 2,000 | 12,900 | 30,100 | 65,000 |
| 338/339 | M&B Knit Shirts/W&G Knit Shirts & Blouses | Doz | 800,000 | 800,000 | 100,000 | 100,000 | 210,000 | 490,000 | 2,500.000 |
| 340/640 | M&B Shirts, not knit | Doz | 50.000 | 50,000 | 12,000 | 12,000 | 187,800 | 438,200 | 750,000 |
| 345 | Sweaters | Doz | 35,000 | 35,000 | 8,000 | 8,000 | 2,400 | 5.600 | 94,000 |
| 347/348/647/648 | M&B, W&G Trousers, Breeches & Shorts | Doz | 917,000 | 917,000 | 229,000 | 229,000 | 212,400 | 495,600 | 3.000,000 |
| 352/652 | Underwear | Doz | 226,000 | 226,000 | 56,000 | 56,000 | 10,800 | 25,200 | 600,000 |
| 438 | Knit Shirts & Blouses | Doz | 13,000 | 13,000 | 3,000 | 3,000 | 17,400 | 40,600 | 90.000 |
| 445/446 | M&B, W&G Sweaters | Doz | 39,000 | 39,000 | 9,000 | 9,000 | 4,200 | 9,800 | 110,000 |
| 638/639 | M&B Knit Shirts/W&G Knit Shirts & Blouses | Doz | 207,000 | 207,000 | 51,000 | 51,000 | 115,200 | 268,800 | 900,000 |
| 645/646 | M&B/W&G Sweaters | Doz | 57.000 | 57,000 | 14,000 | 14,000 | 32,400 | 75,600 | 250,000 |
| | | | 2,837,000 | 2,837,000 | 604,000 | 604,000 | 959,100 | 2,237,900 | 10,079,000 |

ANNEX A2

MINISTRY OF COMMERCE/EXPORT QUOTAS MANAGEMENT COMMITTEE

ALLOCATION OF THE FUNDAMENTAL QUOTAS FOR THE FIRST SEMESTER OF FY 1999 (FQ1)

EFFCTIVE FROM 01 JANUARY 1999

UNIT . DOZ

| ID | COMPANY NAME | 331/631 | 334/634 | 335/635 | 338/339 | 340/640 | 345 | 347/348/647/648 | 352/652 | 438 | 445/446 | 638/639 | 645/646 |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | FQ1 | FQ1 | FQ1 | FQ1 | FQ1 | FQ1 | FQ1 | FQ1 | FQ1 | FQ1 | FQ1 | FQ1 |
| 1 | Beigian | - | - | - | 12.233 | - | - | 4.468 | - | - | - | 5 286 | - |
| 2 | Best Honour | - | - | - | - | - | - | 17.563 | - | - | - | - | - |
| 3 | Blcomex | - | - | - | - | - | - | - | 4.000 | - | - | | - |
| 4 | Broadland | - | - | - | 3.228 | - | - | 12.924 | - | - | - | 4.676 | 662 |
| 5 | Bumin/Ex Golden Time | - | - | - | - | - | - | - | - | - | - | - | - |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 6 | Cambodia Blue bird | - | - | - | 659 | - | - | 2.804 | - | - | - | - | - |
| 7 | Cambodia Castle Peak | - | 4.147 | - | - | - | - | 10 287 | - | - | - | 150 | - |
| 8 | Combodia CPG | - | 1.832 | 245 | - | - | - | 4.516 | - | - | - | - | - |
| 9 | Cambodia Doneunion | - | - | | 3.338 | - | - | - | - | - | - | - | - |
| 10 | Cambodia Embroadery | - | 1 962 | - | - | - | - | - | - | - | - | - | - |
| 11 | Combodia Garment | - | - | - | 38.055 | - | - | 3.158 | 385 | - | - | 1.554 | 6 |
| 12 | Combodia H.K | - | - | - | 60.092 | - | - | 42.341 | - | - | - | 1.158 | - |
| 13 | Cambodia Sportwear | - | - | - | 140 | - | - | 22.794 | - | - | - | - | - |
| 14 | Cambodia Tatsumi | - | - | - | - | - | - | - | - | - | - | - | - |
| 15 | Cambo Tex H.K | - | - | - | 17.195 | - | - | 16 331 | - | - | - | 8.877 | - |
| 16 | Cameo International | - | 573 | - | - | - | - | 6.447 | - | - | - | - | - |
| 17 | Century Rich | - | - | - | - | - | - | - | - | - | 1.692 | - | 1 87[illegible] |
| 18 | Cheer View | - | - | - | - | - | - | 1 849 | - | - | - | - | - |
| 19 | Chu Hsing | - | 1.992 | 300 | 22 | 3.034 | - | 107 763 | - | - | - | - | - |
| 20 | Chueng Hing | - | - | - | - | - | - | - | - | - | - | - | - |
| 21 | City New | - | - | - | 22.087 | 5 | - | 5.519 | 102.373 | - | - | 152 | 3 |
| 22 | Concept Garment | - | - | - | 979 | - | - | 27.527 | - | - | - | - | - |
| 23 | C-One Cambodia | - | - | - | 350 | 19.173 | - | 924 | - | - | - | - | - |
| 24 | Da Joo | - | - | - | 11.947 | - | 552 | 1.222 | - | - | - | - | - |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 25 | Duson Cambodia | - | - | 370 | - | - | - | 3,542 | - | - | - | - | - |
| 26 | Emperor Garment | - | - | - | 24,787 | - | - | 7,413 | - | - | - | 9,058 | - |
| 27 | Entergrity Apparel | - | - | - | - | - | - | 80 | - | - | - | - | - |
| 28 | Enter Bright | - | 42 | - | 4,455 | - | - | 148 | - | - | - | 118 | - |
| 29 | Eternal Way | - | - | - | - | 406 | - | - | - | - | - | - | - |
| 30 | Enternity Apparel | - | - | - | - | - | - | - | - | - | - | - | - |
| 31 | Evergreen | - | 630 | 480 | 15,460 | - | - | 1,415 | - | - | - | - | - |
| 32 | F.Y Cambodia | - | 522 | - | - | - | - | 1,638 | - | - | - | - | - |
| 33 | Fame Cambodia | - | - | - | - | - | - | | - | - | 640 | | - |
| 34 | Flying Dragon | - | - | - | 65 | - | - | 2,648 | - | - | - | 3,498 | - |
| 35 | Forum Garment | - | - | - | 1,068 | - | - | 805 | - | - | - | 5,569 | - |
| 36 | Four Season | - | - | - | - | - | - | 11,141 | - | - | - | - | - |
